| | | | |
|---|---|---|---|
| Minnesota Department of Education | **មណ្ឌលសិក្សាស្រុក ដែលមាតាបិតាសិស្សរស់នៅ :** _____ | **កាលបរិច្ឆេទប្រជុំ IEP :** _____/_____/_____ | **កម្មវិធីអប់រំជាលក្ខណៈ បុគ្គល (IEP)** |
| 12/10 | **កាលបរិច្ឆេទចំពោះការវាយតម្លៃទូលំទូលាយចុងក្រោយ :** | | |

## ព័ត៌មានអត្តសញ្ញាណកម្ម

ឈ្មោះសិស្ស : _____

MARSS ID #: _____

ភេទ : ☐ ប ☐ ស

ថ្ងៃខែឆ្នាំកំណើត : _____/_____/_____

សាលា : _____

ថ្នាក់ : _____

មណ្ឌលសិក្សាស្រុកដែលជាអ្នកផ្តល់សេវា
(ឈ្មោះ/លេខ) : _____

អាសយដ្ឋានសាលា (សូមផ្តល់អាសយដ្ឋានផ្ទៃសំបុត្រ និងអាសយដ្ឋានផ្លូវផ្ទាល់ បើខុសគ្នា) :

_____

_____

ឈ្មោះមាតាបិតា/អាណាព្យាបាល : _____

_____

ទំនាក់ទំនងជាមួយសិស្ស : _____

អាសយដ្ឋាន : _____

_____

លេខទូរស័ព្ទ (លេខប្រើពេលថ្ងៃ/លេខប្រើពេលយប់) :

_____/_____

លេខទូរស័ព្ទ (ចល័ត) : _____

លេខទូរសារ : _____

អ៊ីម៉ែល : _____

## ក្រុម IEP

| ឈ្មោះសមាជិកក្រុមដែលមានវត្តមាន : | តួនាទី : |
|---|---|
| | មាតាបិតា |
| លេខទូរស័ព្ទ : | ប្រធាន IEP |
| | តំណាងមណ្ឌលសិក្សាស្រុក ដែលមានសតម្ភភាពពេញលេញ |
| | គ្រូផ្តល់ការអប់រំពិសេស |
| | គ្រូបង្រៀនម៉ោងសិក្សាធម្មតា |
| | |
| | |

ប្រភេទនៃពិការភាពចម្បងរបស់កុមារ :

- ❑ អត្តវិស័យប្លែកពីធម្មតា
- ❑ ថ្លង់ ខ្វាក់
- ❑ ថ្លង់ និងពិបាកស្តាប់
- ❑ ពិការភាពចំពោះការលូតលាស់ផ្នែកការយល់ដឹង
- ❑ ពិការភាពលើការលូតលាស់សតិបញ្ញា
- ❑ ពិការភាពផ្នែកអារម្មណ៍ ឬអាកប្បកិរិយា
- ❑ ពិការភាពផ្នែកសុខភាពផ្សេងទៀត
- ❑ ពិការភាពលើរាងកាយ
- ❑ ពិការធ្ងន់ធ្ងរ ច្រើនផ្នែក
- ❑ ពិការភាពចំពោះការរៀនសូត្រ
- ❑ ពិការភាពផ្នែកការនិយាយ ឬភាសា
- ❑ ភ្នែកពិបាកមើល
- ❑ របួសខួរក្បាលធ្ងន់ធ្ងរ

ភាសាចម្បងដែលប្រើនៅផ្ទះរបស់សិស្ស : _____

ភាសាចម្បងរបស់សិស្ស : _____

ត្រូវការអ្នកបកប្រែភាសា ក្នុងការទទួលសេវាទេ? □ បាទ/ចាស □ ទេ

ត្រូវការអ្នកបកប្រែភាសាក្នុងដំណើរការផ្លូវច្បាប់ទេ? □ បាទ/ចាស □ ទេ

## ការរាយការណ៍លើការរីកចំរើន

តើពេលណាត្រូវធ្វើរបាយការណ៍ចំពោះការរីកចំរើន ឈានទៅរកគោលបំណងប្រចាំឆ្នាំ ដល់មាតាបិតាសិស្ស?

## ពន្យារពេលឆ្នាំសិក្សា

តើសេវាពន្យារពេលចំពោះឆ្នាំសិក្សា ចាំបាច់ទេសំរាប់សិស្សរូបនេះ? ☐ បាទ/ចាស ☐ ទេ ☐ ត្រូវការទិន្នន័យបន្ថែម

បើឆ្លើយថា បាទ/ចាស សេវាទាំងនោះត្រូវតែមានរៀបរាប់នៅក្នុង IEP នេះ ឬនៅក្នុងឯកសារភ្ជាប់ ។

**FOR AGENCY USE ONLY (Not part of IEP. See IEP instructions for code explanations.)**

**MARSS/Tuition Billing/Child Count data:**

**Primary Disability Code: _____** **Instructional Setting Code:_____**

| **កំរិតជោគជ័យលើការសិក្សាបច្ចុប្បន្ន និងលទ្ធភាពជំនះបានលើពិការភាព គោលបំណង និងការវាស់វែងលើការរីកចំរើន :** |
|---|
| កំរិតបច្ចុប្បន្នចំពោះភាពជោគជ័យលើកសិក្សា និងភាពជំនះលើពិការភាព : កំរិតបច្ចុប្បន្នចំពោះភាពជោគជ័យលើការសិក្សា និងភាពជំនះលើពិការភាព (PLAAFP) គឺជាសេចក្ដីសង្ខេបបែបចំរុះនៃទិន្ន័យយកចេញពីប្រភពទាំងអស់ ដោយរួមទាំងមាតាបិតាសិស្សផងដែរ ។<br>• សំរាប់ *សិស្សមត្តេយ្យ* ត្រូវរៀបរាប់ថាតើពិការភាពរបស់គេ មានការប៉ះពាល់ដល់ការចូលរួមក្នុងសកម្មភាព យ៉ាងដូចម្ដេច ។<br>• សំរាប់ *សិស្ស K-12* ត្រូវរៀបរាប់ថាតើពិការភាពរបស់គេ មានការប៉ះពាល់យ៉ាងដូចម្ដេចចំពោះការចូលរួម និងការសម្រេចបាន នៅក្នុងកម្មវិធីអប់រំទូទៅ ។<br>• លើសពីនេះទៅទៀត សំរាប់សិស្សដែលមានអាយុចាប់ពី 14-21 ឆ្នាំ ត្រូវបញ្ជាក់ការដោះស្រាយនៅកំរិតថ្នាក់បច្ចុប្បន្ន ចំពោះការជោគជ័យក្នុងការសិក្សានៅក្នុងផ្នែកអន្តរកាលនីមួយៗ ។ |
| ____ នៃ ____ គោលបំណងប្រចាំឆ្នាំដែលអាចវាស់វែងបាន រួមទាំងការសិក្សា និងការជំនះលើពិការភាព ជាមួនឹងបទដ្ឋានវាស់វែង ឬទិសដៅរយៈពេលខ្លី : |
| ការរីកចំរើនឆ្ពោះទៅកាន់ការសម្រេចបានទ្ធូវគោលបំណងប្រចាំឆ្នាំនេះ :<br><br>ការរីកចំរើនគិតមកត្រឹម _____<br>(កាលបរិច្ឆេទ) |
| ____ នៃ ____ គោលបំណងប្រចាំឆ្នាំដែលអាចវាស់វែងបាន រួមទាំងការសិក្សា និងការជំនះលើពិការភាព ជាមួនឹងបទដ្ឋានវាស់វែង ឬទិសដៅរយៈពេលខ្លី : |

| **ការវិតជោគជ័យលើការសិក្សាបច្ចុប្បន្ន និងលទ្ធភាពជំនះបានលើពិការភាព គោលបំណង និងការវាស់វែងលើការរីកចំរើន :** |
|---|
| ការរីកចំរើនឆ្ពោះទៅកាន់ការសម្រេចបានន្ទូវគោលបំណងប្រចាំឆ្នាំនេះ :<br><br>ការរីកចំរើនគិតមកត្រឹម _____<br>(កាលបរិច្ឆេទ) |
| ____ នៃ ____ គោលបំណងប្រចាំឆ្នាំដែលអាចវាស់វែងបាន រួមទាំងការសិក្សា និងការជំនះលើពិការភាព ជាមួនឹងបទដ្ឋានវាស់វែង ឬទិសដៅរយៈពេលខ្លី : |
| ការរីកចំរើនឆ្ពោះទៅកាន់ការសម្រេចបានន្ទូវគោលបំណងប្រចាំឆ្នាំនេះ :<br><br>ការរីកចំរើនគិតមកត្រឹម _____<br>(កាលបរិច្ឆេទ) |
| ____ នៃ ____ គោលបំណងប្រចាំឆ្នាំដែលអាចវាស់វែងបាន រួមទាំងការសិក្សា និងការជំនះលើពិការភាព ជាមួនឹងបទដ្ឋានវាស់វែង ឬទិសដៅរយៈពេលខ្លី : |
| ការរីកចំរើនឆ្ពោះទៅកាន់ការសម្រេចបានន្ទូវគោលបំណងប្រចាំឆ្នាំនេះ :<br><br>ការរីកចំរើនគិតមកត្រឹម _____<br>(កាលបរិច្ឆេទ) |

| **សេវាអន្តរកាល**<br>**(ព័ត៌មានអន្តរកាលដែលត្រូវធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ)** |
|---|
| **ក : គោលបំណងក្រោយការរៀនចប់មធ្យមសិក្សា ដែលអាចវាស់វែងបាន :** |
| ការអប់រំ និងការបណ្តុះបណ្តាល ក្រោយរៀនចប់មធ្យមសិក្សា :<br><br>ការងារ :<br><br>ការរស់នៅដោយឯករាជ្យ (តាមភាពសមរម្យ ហើយអាចរួមបញ្ចូលនូវ សកម្មភាពសំរាក និងកំសាន្តកាយ ការចូលរួមក្នុងសហគមន៍ និងការរស់នៅឯផ្ទះ) : |

**ខ : មុខវិជ្ជាសិក្សា :**

| **ឆ្នាំសិក្សា** | **កំរិតថ្នាក់** | **មុខវិជ្ជា** |
|---|---|---|
| | 9 | |
| | 10 | |
| | 11 | |
| | 12 | |
| ខែ និងឆ្នាំ ដែលរំពឹងថាសិស្សនឹងរៀនចប់ ____/____ | | |

**គ : សេវាអន្តរកាល :**

| **សេវា** | **សកម្មភាព** | **ភ្នាក់ងារផ្តល់សេវានៅក្នុង IEP** |
|---|---|---|
| ការបង្រៀន (ដូចជា ការបង្រៀនតាមបំណិនជាក់លាក់ ការអប់រំធម្មតា ការអប់រំដើម្បីការងារ និងបច្ចេកទេស) : | | |

| សេវាអន្តរកាល<br>(ព័ត៌មានអន្តរកាលដែលត្រូវធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ) | | |
|---|---|---|
| សេវាដែលពាក់ព័ន្ធ : | | |
| ការចូលរួមនៅក្នុងសហគមន៍ : | | |
| ទិសដៅការអភិវឌ្ឍន៍ការងារ និងទិសដៅផ្សេងទៀត សំរាប់ការរស់នៅ<br>ក្រោយរៀនចប់នៅមធ្យមសិក្សា : | | |
| បើសមរម្យ ត្រូវផ្តល់ជូននូវបំណិនជីវិតសំរាប់ការរស់នៅប្រចាំថ្ងៃ និងធ្វើការវាយតម្លៃ<br>ការប្រើចលនារាងកាយជំនះលើពិការភាព : | | |

| ការផ្ទេរសិទ្ធិពេលសិស្សគ្រប់អាយុជាមនុស្សពេញវ័យ |
|---|
| សិទ្ធិទាំងអស់ដែលមាតាបិតាសិស្សមាន ដោយស្ថិតក្រោមផ្នែកខ IDEA និងច្បាប់ផ្សេងទៀតរបស់រដ្ឋដែលពាក់ព័ន្ធ នឹងត្រូវផ្ទេរទៅឱ្យសិស្ស ពេលដែលសិស្សមានអាយុជាមនុស្សពេញវ័យ (18ឆ្នាំ) ប្រសិនបើមិនមានការចាត់តាំងឱ្យមានអាណាព្យាបាល ឬអ្នកទទួលខុសត្រូវស្របច្បាប់ទេនោះ ។<br>សិស្សនឹងបានទទួលដំណឹងអំពីការផ្ទេរសិទ្ធិនេះ នៅថ្ងៃទី _____ (កាលបរិច្ឆេទ) |

| សេវា និងការកែសម្រួល | | | | | |
|---|---|---|---|---|---|
| **ការអប់រំពិសេស និងសេវានានាដែលពាក់ព័ន្ធ (ការបង្រៀនធម្មតាៗដោយផ្ទាល់ និងសេវាដែលត្រូវផ្តល់ជូនដោយផ្ទាល់) ។** | | | | | |
| សេចក្តីថ្លែងអំពីការអប់រំពិសេស និងសេវានានាដែលពាក់ព័ន្ធ | កាលបរិច្ឆេទ ចាប់ផ្តើម | ចំនួនដង/សប្តាហ៍ /ខែ/ផ្សេងទៀត (ដូចជាប្រចាំថ្ងៃ Xក្នុងមួយសប្តាហ៍ តេស្តនីមួយៗ) | ចំនួននាទី សំរាប់សេវា មួយដង | ទីកន្លែង (ដូចជាថ្នាក់រៀនធម្មតា ក្រៅថ្នាក់/បន្ទប់ធនធាន បន្ទប់ការអប់រំពិសេស ផ្ទះ) | ការប៉ាន់ស្មានលើចិរវេលាសរុប |
| | | | | | |
| | | | | | |

| សេវា និងការកែសម្រួល | | | | | |
|---|---|---|---|---|---|
| | | | | | |

| ជំនួយ និងសេវាបង្រៀប់ (ការកែសម្រួល ឧបករណ៍បច្ចេកវិជ្ជាសំរាប់ជំនួយ ជំនួយពីជំនួយការរបស់អ្នកឯកទេស ។ល។) | | | | | |
|---|---|---|---|---|---|
| សេចក្ដីផ្ទែងអំពីជំនួយ និងសេវាបង្រៀប់ | កាលបរិច្ឆេទ ចាប់ផ្ដើម | ចំនួនដង/សប្ដាហ៍ /ខែ/ផ្សេងទៀត (ដូចជាប្រចាំថ្ងៃ Xក្នុងមួយសប្ដាហ៍ តេស្ដនីមួយ១) | ចំនួននាទី សំរាប់សេវា មួយដង | ទីកន្លែង (ដូចជាថ្នាក់រៀនធម្មតា ក្រៅថ្នាក់/បន្ទប់ធនធាន បន្ទប់ការអប់រំពិសេស ផ្ទះ) | ការប៉ាន់ស្មានលើថិរវេលាសរុប |
| | | | | | |
| | | | | | |
| | | | | | |

| ការសម្រួលកម្មវិធី និងការជ្រើសជ្រែង សំរាប់បុគ្គលិកសាលា (សម្រួលការបង្ក្រៀនដែលត្រូវផ្ដល់ជូនសិស្ស ឬសមាសធាតុនានានៃកម្មវិធីធម្មតាផ្សេងទៀត សេវាប្រយោល ការបណ្ដុះបណ្ដាលជំនាញជាក់លាក់សំរាប់បុគ្គលិក ការអន្តរាគមន៍ដោយប្រើអាកប្បកិរិយា ។ល។) | | | | | |
|---|---|---|---|---|---|
| សេចក្ដីផ្ទែងអំពីការកែប្រែកម្មវិធី និងការជ្រើសជ្រែង ចំពោះបុគ្គលិកសាលា | កាលបរិច្ឆេទ ចាប់ផ្ដើម | ចំនួនដង/សប្ដាហ៍ /ខែ/ផ្សេងទៀត (ដូចជាប្រចាំថ្ងៃ Xក្នុងមួយសប្ដាហ៍ តេស្ដនីមួយ១) | ចំនួននាទី សំរាប់សេវា មួយដង | ទីកន្លែង (ដូចជាថ្នាក់រៀនធម្មតា ក្រៅថ្នាក់/បន្ទប់ធនធាន បន្ទប់ការអប់រំពិសេស ផ្ទះ) | ការប៉ាន់ស្មានលើថិរវេលាសរុប |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

| ការពន្យល់អំពីបរិយាកាសដែលមានភាពតឹងរ៉ឹងតិចតួច (LRE) |
|---|
| ការពន្យល់ អំពីកត្តា ដែលសិស្សនឹងមិនចូលរួមជាមួយសិស្សមិនពិការ នៅក្នុងថ្នាក់រៀនធម្មតា និងសកម្មភាពផ្សេងទៀត ប្រសិនបើមាន។ *សូមអាន* 34 C.F.R. § 300.320(a)(5) ។ |

| ការវាយតម្លៃរបស់រដ្ឋ សំរាប់គណយ្យេភាពលើភាពស្ទាត់ជំនាញភាសាអង់គ្លេស | |
|---|---|
| **អំណាន/ការសរសេរ** *(ថ្នាក់ K-12)* | **ការស្តាប់/ការនិយាយ** *(ថ្នាក់ K-12)* |
| សិស្សនឹងបានចូលរួមក្នុង : | សិស្សនឹងបានចូលរួមក្នុង : |
| ☐ បញ្ជីត្រួតពិនិត្យអំណាន និងការសរសេរ K-2 (សំអាងលើការសង្កេតរបស់គ្រូ)<br>☐ តេស្តការសិក្សាភាសាអង់គ្លេស (TEAE) (អំណាន/ការសរសេរ) ដោយមិនមានការ កែសម្រួល<br>☐ តេស្តការសិក្សាភាសាអង់គ្លេស (TEAE) ដោយមានការកែសម្រួល | ☐ តារាងការសង្កេតភាសានិយាយរបស់សិស្សនៅរដ្ឋមីណេសូតា (Minnesota-SOLOM) |

| ការវាយតម្លៃរបស់រដ្ឋ សំរាប់គណយ្យេភាព | | |
|---|---|---|
| **អំណាន**<br>*(ថ្នាក់ទី 3, 4, 5, 6, 7, 8 និងថ្នាក់ទី 10)* | **គណិតវិទ្យា**<br>*(ថ្នាក់ទី 3, 4, 5, 6, 7, 8 និងថ្នាក់ទី 11)* | **វិទ្យាសាស្ត្រ**<br>*(ថ្នាក់ទី 5, 8 និងវិទ្យាល័យ)* |
| សិស្សនឹងបានចូលរួមក្នុង : | សិស្សនឹងបានចូលរួមក្នុង : | សិស្សនឹងបានចូលរួមក្នុង : |
| ☐ MCA ដោយមិនចាំបាច់មានការកែសម្រួល<br>☐ MCA ជាមួយនឹងការកែសម្រួល ដូចមានក្នុងតារាង : | ☐ MCA ដោយមិនចាំបាច់មានការកែសម្រួល<br>☐ MCA ជាមួយនឹងការកែសម្រួល ដូចមានក្នុងតារាង : | ☐ MCA ដោយមិនចាំបាច់មានការកែសម្រួល<br>☐ MCA ជាមួយនឹងការកែសម្រួល ដូចមានក្នុងតារាង : |
| ពន្យល់ពីរបៀបដែលថាការកែសម្រួលដែលបានជ្រើសរើសយក<br>គឺជាការតំណាងនូវអ្វីទាំងអស់ដែលប្រើនៅក្នុងថ្នាក់រៀន ។ | ពន្យល់ពីរបៀបដែលថាការកែសម្រួលដែលបានជ្រើសរើសយក<br>គឺជាការតំណាងនូវអ្វីទាំងអស់ដែលប្រើនៅក្នុងថ្នាក់រៀន ។ | ពន្យល់ពីរបៀបដែលថាការកែសម្រួលដែលបានជ្រើសរើសយក<br>គឺជាការតំណាងនូវអ្វីទាំងអស់ដែលប្រើនៅក្នុងថ្នាក់រៀន ។ |
| ☐ MCA-កែប្រែ ជាការវាយតម្លៃដោយវិធីផ្សេងទៀត សំអាងលើបទដ្ឋានជោគជ័យលើកម្មវិធីកែសម្រួលថ្នាក់ទី 5-8 និងថ្នាក់ទី 10 ។ ប្រសិនបើក្រុម IEP កំណត់ថា សិស្សនឹងត្រូវប្រឡង MCA-កែប្រែ IEP របស់សិស្សត្រូវតែ<br>រួមបញ្ចូលផងដែរនូវបទដ្ឋានសំអាងលើគោលបំណង និងទិសដៅ ។ | ☐ MCA-កែប្រែ ជាការវាយតម្លៃដោយវិធីផ្សេងទៀត សំអាងលើបទដ្ឋានជោគជ័យលើកម្មវិធីកែសម្រួលថ្នាក់ទី 5-8 និងថ្នាក់ទី 11 ។ ប្រសិនបើក្រុម IEP កំណត់ថា សិស្សនឹងត្រូវប្រឡង MCA-កែប្រែ IEP របស់សិស្សត្រូវតែ<br>រួមបញ្ចូលផងដែរនូវបទដ្ឋានសំអាងលើគោលបំណង និងទិសដៅ ។ | |

| | | |
|---|---|---|
| សរសេរទុកការសម្រេចចិត្តរបស់ក្រុម IEP: ពន្យល់ពីមូលហេតុ ដែលជំរើសលើការវាយតម្លៃនេះ មានភាពសមរម្យ ។<br><br>☐ តេស្ត MN នៃបំណិនការសិក្សា (MTAS) ជាការវាយតម្លៃមួយផ្សេងទៀត សំអាងលើភាពជោគជ័យលើ បទដ្ឋានមួយផ្សេងទៀត<br><br>សរសេរទុកអំពីការសម្រេចចិត្តរបស់ក្រុម IEP: ពន្យល់ពីមូល ហេតុ ដែលជំរើសលើការវាយតម្លៃនេះ មានភាពសមរម្យ ។ | សរសេរទុកការសម្រេចចិត្តរបស់ក្រុម IEP: ពន្យល់ពីមូលហេតុ ដែលជំរើសលើការវាយតម្លៃនេះ មានភាពសមរម្យ ។<br><br>☐ តេស្ត MN នៃបំណិនការសិក្សា (MTAS) ជាការវាយតម្លៃមួយផ្សេងទៀត សំអាងលើភាពជោគជ័យលើ បទដ្ឋានមួយផ្សេងទៀត<br><br>សរសេរទុកអំពីការសម្រេចចិត្តរបស់ក្រុម IEP: ពន្យល់ពីមូល ហេតុ ដែលជំរើសលើការវាយតម្លៃនេះ មានភាពសមរម្យ ។ | ☐ តេស្ត MN នៃបំណិនការសិក្សា (MTAS) ជាការវាយតម្លៃមួយផ្សេងទៀត សំអាងលើភាពជោគជ័យលើ បទដ្ឋានមួយផ្សេងទៀត<br><br>សរសេរទុកអំពីការសម្រេចចិត្តរបស់ក្រុម IEP: ពន្យល់ពីមូល ហេតុ ដែលជំរើសលើការវាយតម្លៃនេះ មានភាពសមរម្យ ។ |

## កត្តានានាដែលត្រូវបំពេញដើម្បីអាចទទួលបានសញ្ញាប័ត្រ

### ការតម្រូវលើការប្រឡងចេញដើម្បីបានទទួលសញ្ញាប័ត្រ (GRAD)

ការប្រឡងដំបូងនៃអំណាន និងគណិតវិទ្យា GRAD ត្រូវមានភ្ជាប់នៅក្នុង MCA ។ ការប្រឡងវិញ្ញាសរសេរ GRAD ត្រូវធ្វើឡើងដំបូងនៅថ្នាក់ទី 9 ។ សិស្សអាចប្រឡង GRAD ឡើងវិញ ប្រសិនបើគេប្រឡងធ្លាក់លើវិញ្ញាសរសេរ GRAD ឬមួយថាគេមានពិន្ទុទាបជាងកំរិតជោគជ័យជាបទដ្ឋានលើ MCA ឬបានទទួលពិន្ទុជាប់លើអំណាន និងគណិតវិទ្យាដែលមានភ្ជាប់ជាមួយនឹង GRAD ។ ក្រុម IEP អាចកំណត់នូវពិន្ទុដែលត្រូវចាត់ទុកថាជាការប្រឡងជាប់ សំរាប់សិស្សនីមួយៗ ក្រោយពេលការប្រឡង GRAD រួចមក ។

សិស្សនឹងបានចូលរួមក្នុង :

☐ ដោយមិនចាំបាច់កែប្រែ :បញ្ជាក់មុខវិជ្ជា ។

☐ ជាមួយនឹងការកែប្រែ ដូចមានសរសេរក្នុងតារាង : បញ្ជាក់មុខវិជ្ជា ។

ពន្យល់ពីរបៀបដែលថាការកែសម្រួលដែលបានជ្រើសរើស យក គឺជាតំណាងនូវអ្វីទាំងអស់ដែលប្រើនៅក្នុងថ្នាក់រៀន ។

☐ ជាមួយនឹងពិន្ទុដែលចាត់ទុកថាប្រឡងជាប់របស់សិស្សម្នាក់ៗ

បញ្ជាក់មុខវិជ្ជា ។ សរសេរចូលនូវពិន្ទុគោល ហើយពន្យល់ពីមូលហេតុ :

### តេស្តលើបំណិនជាមូលដ្ឋាន (BST)

សិស្សដែលចូលរៀនថ្នាក់ទី 8 ដំបូង នៅឆ្នាំសិក្សា 2004-2005 ឬចូលរៀនមុននេះ អាចប្រឡង BST លើវិញ្ញាសារអំណាន និងគណិតវិទ្យា ដើម្បីបំពេញចំពោះផ្នែកតម្រូវលើការប្រឡងចេញ ។ អំណាន និងគណិត BST ត្រូវបានធ្វើឡើងតែសំរាប់ការប្រឡងឡើងវិញ ។ សិស្សដែលត្រូវប្រឡងឡើងវិញនូវតេស្តវិញ្ញាសារសរសេរ BST ត្រូវប្រឡងវិញ្ញាសារសរសេរ GRAD

សិស្សនឹងបានចូលរួមក្នុង :

☐ ដោយមិនចាំបាច់មានការកែសម្រួល :បញ្ជាក់ពីមុខវិជ្ជា ។

☐ ជាមួយនឹងការកែសម្រួល ដូចមានក្នុងតារាង : បញ្ជាក់ពីមុខវិជ្ជា ។

ពន្យល់ពីរបៀបដែលថាការកែសម្រួលដែលបានជ្រើសរើស យក គឺជាការតំណាងនូវអ្វីទាំងអស់ដែលប្រើនៅក្នុងថ្នាក់រៀន ។

☐ ជាមួយនឹងការកែសម្រួល/ពិន្ទុប្រឡងជាប់របស់សិស្សនីមួយ១ ក្រោយពីការប្រឡងលើកទី ១ :បញ្ជាក់ពីមុខវិជ្ជា សរសេរទុកនូវពិន្ទុគោល ការកែសម្រួលដែលបានជ្រើសរើស និងមូលហេតុ :

**ឬ**

☐ ជាមួយនឹងការប្រឡងដោយវិធីផ្សេងទៀតរបស់ MDE (ពិន្ទុប្រឡងជាប់របស់សិស្សនីមួយ១) :បញ្ជាក់ពីមុខវិជ្ជា ហើយសរសេរទុកនូវពិន្ទុគោល :

☐ ជាមួយនឹងការប្រឡង MN ដោយវិធីផ្សេងទៀត-វិញ្ញាសារសរសេរ

☐ វិញ្ញាសារសរសេរ

**MCA- កែសម្រួល ឬ MTAS**

សិស្សក៏ប្រហែលជាត្រូវបំពេញភាពតម្រូវចំពោះការរៀនឱ្យបានចប់ តាមរយៈពិន្ទុការប្រឡងជាប់របស់សិស្សនីមួយ១ ដែលបានកំណត់ឡើងនៅក្នុងការប្រឡងដោយវិធីផ្សេងទៀត នៅក្នុងវិញ្ញាសារអំណាន និងគណិតវិទ្យា ។

☐ MCA-កែសម្រួល (ពិន្ទុប្រឡងជាប់របស់សិស្សនីមួយ) ប្រសិនបើជ្រើសយកវិញ្ញាសារគណនេយ្យភាពសរសេរ ឬគណិតវិទ្យាខាងលើ

☐ អំណាន ☐ គណិតវិទ្យា

☐ MTAS (ពិន្ទុប្រឡងជាប់របស់សិស្សនីមួយ១) ប្រសិនបើជ្រើសយកវិញ្ញាសារគណនេយ្យភាពសរសេរ ឬគណិតវិទ្យាខាងលើ

☐ អំណាន ☐ គណិតវិទ្យា

| កំណត់ត្រា ឬស្ថានភាពចំពោះភាពស្ទាត់ជំនាញ ដែលសិស្សអាចសម្រេចបានតួវតម្រូវការនានាលើការប្រឡងចេញយកសញ្ញាប័ត្រ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| សម្រាប់ការប្រឡងជាប់ ឬប្រឡងជាប់នៅរដ្ឋ ត្រូវកត់ត្រាកាលបរិច្ឆេទដែលបានប្រឡងជាប់/សំរាប់ការប្រឡងជាប់ ឬពិន្ទុដែលសិស្សនីមួយ១ត្រូវប្រឡងជាប់ ត្រូវកត់ត្រានូវពិន្ទ និងកាលបរិច្ឆេទដែលបានប្រឡងជាប់ | | | | | | | | | | | |
| | ជាប់ រដ្ឋ | ប្រឡងជាប់ | | | | | ពិន្ទុប្រឡងជាប់របស់សិស្សនីមួយ១ | | | | |
| **មុខវិជ្ជា** | **BST** | **GRAD** | **MCA** | **MCA-MOD** | **MTAS** | **ការវាយតម្លៃដោយវិធីផ្សេងរបស់រដ្ឋមីណេសូតា-ការសរសេរ** | **BST ឬ ការវាយតម្លៃវិធីផ្សេង MDE** | **GRAD** | **MCA-MOD** | **MTAS** | **ការវាយតម្លៃដោយវិធីផ្សេងរបស់រដ្ឋមីណេសូតា-ការសរសេរ** |
| **អំណាន (ថ្នាក់ទី 10)** | | | | | | | | | | | |
| **គណិតវិទ្យា (ថ្នាក់ទី 11)** | | | | | | | | | | | |
| **ការសរសេរ (ថ្នាក់ទី 9)** | | | | | | | | | | | |

☐ ការប្រឡងទូទាំងរដ្ឋ **មិនមែន** ធ្វើឡើងនៅតាមកំរិតថ្នាក់ ដែលគ្របដណ្ដប់ដោយ IEP នេះឡើយ ។

☐ ការប្រឡងទូទាំងរដ្ឋ **គឺជា** ការប្រឡងនៅតាមកំរិតថ្នាក់ ដែលគ្របដណ្ដប់ដោយ IEP នេះ ។ (បើគួសលើប្រអប់នេះ សូមបន្ត្ក្នុងតារាងខាងក្រោម)

| | | |
|---|---|---|
| **ការប្រឡងទូទាំងរដ្ឋ :** ចូរសរសេរចំពោះការ ប្រឡងនីមួយ១ ដែលធ្វើឡើងទូទាំងរដ្ឋ សំរាប់សិស្សទាំងអស់នៅក្នុងកំរិតនេះ ។ | **តើការប្រឡងមានភាពសមរម្ម សម្រាប់សិស្សទេ?** *បង្ហាញដោយ បាទ/ចាស ឬទេ សំរាប់ការប្រឡងនីមួយ១ ។* | បើឆ្លើយថា **បាទ/ចាស** សម្រាប់ការប្រឡងនីមួយ១ ត្រូវបង្ហាញថាតើសិស្សត្រូវការវិញ្ញាសារបែបកែសម្រួល ហើយអ្វីខ្លះដែលត្រូវការកែសម្រួល ។<br><br>បើឆ្លើយថា **ទេ** សរសេរអំពីមូលហេតុដែលថាការប្រឡងទូទាំងស្រុកមិនសមរម្យចំពោះសិស្សរូបនេះ **ហើយ** បង្ហាញនូវអ្វីដែលជាការប្រឡងដោយប្រើវិធីផ្សេងទៀត ដែលត្រូវឱ្យសិស្សប្រឡង ព្រមទាំងប្រាប់ពីមូលហេតុដែលថាការកែសម្រួលនេះមានភាពសមរម្យចំពោះសិស្ស ។ |

**ការជូនដំណឹងដល់មាតាបិតាសិស្ស អំពីការប្រឡងដោយប្រើវិធីផ្សេង**

☐ បើគេគួសលើប្រអប់នេះ ភាពជោគជ័យលើការសិក្សារស់កូនអ្នក នឹងត្រូវវាស់វែងដោយប្រើបទដ្ឋានជោគជ័យលើការសិក្សាបែបកែសម្រួល ឬបទដ្ឋានភាពជោគជ័យលើការសិក្សាដោយប្រើវិធីផ្សេង ដូចបង្ហាញជូនពីខាងលើស្រាប់ លើការប្រឡងទូទាំងរដ្ឋ ឬទូទាំងមណ្ឌលសិក្សាស្រុក ។ ភាពស្ទាត់ជំនាញលើការសិក្សារបស់កូនអ្នក ជានិច្ចកាលត្រូវតែសំអាងលើបទដ្ឋានខ្ជឹមសារការសិក្សា សំរាប់កំរិតថ្នាក់របស់គេ ។

*បែបបទនេះអាចរកបានតាមទ្រង់ទ្រាយផ្សេងទៀត ។ សូមទំនាក់ទំនងជាមួយនឹងប្រធាន IEP ដើម្បីស្នើសុំបែបបទនេះ តាមទ្រង់ទ្រាយផ្សេងទៀត ។*

*ក្រសួងអប់រំរដ្ឋមីណេសូតា (MDE) បានបង្កើតបែបបទដំណើរការផ្លូវច្បាប់តាមការណែនាំ សំរាប់ប្រើប្រាស់ដោយសហគមន៍អ្នកអប់រំ ។ យើងមិនតម្រូវឱ្យមណ្ឌលសិក្សាស្រុក និងមាតាបិតាសិស្ស ថាត្រូវតែប្រើបែបបទគំរូនេះទេ ។ បំណងនៃការបង្កើតបែបបទទាំងនេះ គឺសំរាប់ផ្ដល់ជូននូវមគ្គុទ្ទេសក៍ដែលមានប្រយោជន៍ និងជាឯកសារគំរូ ដែលរួមទាំង សមាសធាតុផ្សេង១នៃទិន្នន័យដែលត្រូវការ សំរាប់ដើរតាមភាពតម្រូវលើដំណើរការផ្លូវច្បាប់ចំពោះការអប់រំពិសេស ។ បែបបទនេះអាចធ្វើការ កែសម្រួលបានតាមសភាពជាក់ស្ដែង ។*

**កម្មវិធីអប់រំជាលក្ខណៈបុគ្គល (IEP)**

**មគ្គុទ្ទេសក៍ចំពោះការប្រើបែបបទ**

គោលបំណងនៃការចងក្រងឯកសារ IEP គឺដើម្បីឱ្យមានកំណត់ត្រាឯកសារជាលាយលក្ខណ៍អក្សរ ចំពោះការសម្រេចចិត្តនានាដែលបានធ្វើឡើង នៅឯការប្រជុំ IEP ដែលមាតាបិតាសិស្ស និងបុគ្គលិករបស់សាលា បានធ្វើការសម្រេចចិត្តរួមគ្នាអំពីកម្មវិធីអប់រំ ចំពោះសិស្សពិការ ។ ម៉ូដែល MDE នៃបែបបទ IEP ផ្តល់ឱ្យយើងនូវបែបបទគំរូសំរាប់ប្រើនៅក្នុង IEP ដែលជាការដើរស្របគ្នាជាមួយនឹងច្បាប់របស់រដ្ឋ និងច្បាប់របស់សហព័ន្ធ ហើយផ្តល់ឱ្យយើងនូវព័ត៌មានដែលមានសារៈប្រយោជន៍ ដល់បុគ្គលិកសាលា និងមាតាបិតាសិស្ស ។ ខណៈពេលដែលយើងមិនតម្រូវឱ្យប្រើនៅគ្រប់ផ្នែកទាំងអស់នៃម៉ូដែល IEP សំរាប់សិស្សពិការទាំងអស់ក็ដោយ ក็ការខកខានបំពេញនូវព័ត៌មានជាក់លាក់ណាមួយ ដែលជាការតម្រូវ អាចចាត់ទុកជាការមិនធ្វើតាម ហើយនាំឱ្យបាត់បង់នូវប្រសិទ្ធិភាពនៃការបង្រៀន ។ គោលការណ៍ណែនាំនេះ នឹងអាចជួយដល់បុគ្គលិកសាលា ដើម្បីធានាបានថា ព័ត៌មានដែលត្រូវការទាំងអស់ ត្រូវបានសរសេរបញ្ចូលទៅក្នុង IEP ដើម្បីជួយឱ្យការព្យាយាមរបស់មណ្ឌលសិក្សាស្រុក ចំពោះការអប់រំដល់សិស្សពិការ មានប្រសិទ្ធិភាពខ្ពស់ ។

**ផ្នែកក្បាលនៃ IEP:**

| | | | |
|---|---|---|---|
| Minnesota Department of Education | **មណ្ឌលសិក្សាស្រុក ដែលមាតាបិតាសិស្សរស់នៅ :** _____ | **កាលបរិច្ឆេទប្រជុំ IEP :** _____/_____/_____ | **កម្មវិធីអប់រំជាលក្ខណៈបុគ្គល (IEP)** |
| 12/10 | **កាលបរិច្ឆេទចំពោះការវាយតម្លៃទូលំទូលាយចុងក្រោយ :** | | |

សរសេរឈ្មោះ និងលេខរបស់មាតាបិតា នៅក្នុងមណ្ឌលសិក្សាស្រុកដែលខ្លួនរស់នៅ ឬមួយថាបើមាតាបិតាចុះឈ្មោះឱ្យកូនខ្លួនចូលរៀននៅឯសាលាឯកជន ឬយកកូនទៅចុះឈ្មោះចូលរៀននៅឯ មណ្ឌលសិក្សាស្រុកផ្សេងទៀត ត្រូវកត់ឈ្មោះ និងលេខរបស់សាលាឯកជន ឬមណ្ឌលសិក្សាស្រុកនោះទុក ។ ព័ត៌មាននេះមានសារៈសំខាន់ សំរាប់ផ្ញើប័ណ្ណទារប្រាក់ថ្ងៃបង្រៀនបន្ថែម និងសំរាប់ទាក់ទង ចំពោះបញ្ហាផ្សេងទៀត ពាក់ព័ន្ធនឹងរឿងប្រាក់កាស ពេលដែលគ្រួសារសិស្ស ត្រូវពាក់ព័ន្ធជាមួយនឹងមណ្ឌលសិក្សាស្រុក ច្រើនជាងមួយ ។

កត់ត្រាទុកនូវកាលបរិច្ឆេទប្រជុំ IEP (ឬកាលបរិច្ឆេទចំពោះការប្រជុំដំបូងនៃការប្រជុំដែលនឹងកើតមានជាបន្ត១ៗគ្នា) ដែលយក IEP បានស្នើឡើងមកពិនិត្យឡើងវិញ ឬយកវាមកបង្កើតឡើង ។ កំណត់ត្រានេះ នឹងអាចជួយយើងចំពោះបទដ្ឋានលើការជួយ ក្នុងការកំណត់ថាតើ IEP ដែលបានស្នើឡើង ត្រូវយកមកប្រើនៅពេលណា ចំពោះមាតាបិតាសិស្ស ។ វា ជារឿងសំខាន់ដែលត្រូវចងចាំថា ពេលណាដែល IEP ដំបូងត្រូវបានស្នើឡើង ឬគេស្នើសុំកែប្រែលើ IEP វាត្រូវតែដើរតាមកំណត់ត្រាដែលបានសរសេរទុកកាលពីលើកមុន និងដើរតាមបែបបទ ចំពោះការយល់ព្រម/បដិសេធ របស់មាតាបិតា ។

ក្រុម IEP ត្រូវយកឯកសារនេះមកពិនិត្យឡើងវិញ ហើយកែសម្រួល IEP របស់សិស្សតាមការពិតជាក់ស្តែង តែមិនឱ្យតិចជាងមួយដងក្នុងមួយឆ្នាំ ។ IEP បច្ចុប្បន្ន ត្រូវតែមាន សុពលភាពនៅដើមឆ្នាំសិក្សានីមួយៗ ។

ត្រូវកត់ត្រានូវកាលបរិច្ឆេទនៃរបាយការណ៍ការវាយតម្លៃទូលំទូលាយជាចុងក្រោយ ។ កំណត់ត្រានេះ នឹងអាចជួយដល់ក្រុមបាន ចំពោះព័ត៌មានអំពីអាយុនៃទិន្នន័យដែលត្រូវយកមកប្រើធ្វើការវាយតម្លៃ ក្នុងការបង្កើតកម្មវិធី ហើយក្នុងការធានាថា ការវាយតម្លៃត្រូវបានធ្វើឡើង មិនតិចជាងបីឆ្នាំម្តងឡើយ ។

**ព័ត៌មានអត្តសញ្ញាណកម្ម :**

| ព័ត៌មានអត្តសញ្ញាណកម្ម | | | |
|---|---|---|---|
| ឈ្មោះសិស្ស :<br>MARSS ID # | ភេទ :<br>ប<br>ស | ថ្នាក់ : | ថ្ងៃខែឆ្នាំកំណើត : |
| អាសយដ្ឋាន : | សាលា :<br>មណ្ឌលសិក្សាស្រុកទទួលខុសត្រូវ (ឈ្មោះ/លេខ) : | | |
| ឈ្មោះមាតាបិតា/អាណាព្យាបាល ទំនាក់ទំនងជាមួយសិស្ស អាសយដ្ឋាន លេខទូរស័ព្ទ :: | ប្រភេទនៃពិការភាពរបស់សិស្ស :<br>អត្តវិស័យប្លែកពីធម្មតា<br>ថ្លង់ ខ្វាក់<br>អារម្មណ៍ ឬអត្តចរិកខុសពីធម្មតា<br>ថ្លង់ និងពិបាកស្តាប់<br>ពិការភាពចំពោះការលូតលាស់ផ្នែក<br>ការយល់ដឹង<br>ពិការភាពផ្នែកសុខភាពផ្សេងទៀត<br>ពិការភាពលើរាងកាយ<br>ពិការធ្ងន់ធ្ងរ ច្រើនផ្នែក<br>ពិការភាពចំពោះការរៀនសូត្រ<br>ពិការភាពផ្នែកការនិយាយ ឬភាសា<br>ភ្នែកពិបាកមើល<br>របួសខួរក្បាលធ្ងន់ធ្ងរ<br>ពិការភាពលើការលូតលាស់សតិបញ្ញា | | |

កត់ត្រាឈ្មោះសិស្ស លេខ MARSS និងអាសយដ្ឋាន ។ កត់ត្រាឈ្មោះមាតាបិតាសិស្ស និងលេខទូរស័ព្ទ ទំនាក់ទំនងរបស់មាតាបិតា/អាណាព្យាបាលចំពោះសិស្ស និងអាសយដ្ឋាន បើសិនជាវាខុសពីអាសយដ្ឋានរបស់សិស្ស ឬអ្នកទាំងពីរមានអាសយដ្ឋានរៀងៗខ្លួន ។

ត្រូវកត់ត្រាភេទរបស់សិស្ស សំរាប់ជាជំនួយលើទិន្នន័យដែលត្រូវយកទៅធ្វើរបាយការណ៍ ។ ចំណាត់ថ្នាក់របស់សិស្សនៅក្នុងឆ្នាំដែល IEP នៅមានសុពលភាព ក៏ត្រូវកត់ត្រាទុក ដោយរួមទាំងថ្ងៃខែឆ្នាំកំណើតរបស់សិស្សផងដែរ ។ ចំណុចទាំងនេះអាចជា សមាសធាតុទិន្នន័យដែលមានសារៈប្រយោជន៍ផងដែរ ។

ព័ត៌មានរបស់សិស្សនៅសាលា និងនៅឯមណ្ឌលសិក្សាស្រុកដែលមានតួនាទីទទួលខុសត្រូវ ចំពោះការសិក្សារបស់គេ ក៏ត្រូវកត់ចូលផងដែរ ។ ប្រសិនបើសិស្សចូលរៀននៅសាលាឯកជនតាមជំរើសរបស់ខ្លួន យើងអាចសរសេរចូលតែឈ្មោះ និងលេខរបស់សាលាឯកជុននោះ គឺជាការគ្រប់គ្រាន់ហើយ ។

**ក្រុម IEP:**

| ក្រុម IEP | |
|---|---|
| ឈ្មោះសមាជិកក្រុមដែលមានវត្តមាន : | តួនាទី : |
| | មាតាបិតា |
| លេខទូរស័ព្ទ :_____ | ប្រធាន IEP |
| | តំណាងមណ្ឌលសិក្សាស្រុក ដែលមានសតម្ភភាពពេញលេញ |
| | គ្រូ ឬអ្នកផ្តល់សេវាអប់រំពិសេស |
| | គ្រូបង្រៀនម៉ោងសិក្សាធម្មតា |
| | |
| | |

មណ្ឌលសិក្សាស្រុក ត្រូវធានាថា ក្រុម IEP នីមួយៗ ចាំបាច់ត្រូវមានសមាសសភាពសមាជិក ដូចខាងក្រោម :

- មាតាបិតាសិស្ស ដែលមានរួមទាំងអាណាព្យាបាលស្របច្បាប់ មាតាបិតាជំនួស និងសាមីសិស្ស បើគេមានអាយុ 18ឆ្នាំ ឬច្រើនជាងនេះ
- យ៉ាងហោចណាស់មានគ្រូចំណេះទូទៅមួយនាក់ចូលរួម ( ប្រសិនបើសិស្ស ឬសិស្សអាចចូលរៀននៅក្នុងថ្នាក់ចំណេះដឹងទូទៅបាន)
- យ៉ាងហោចណាស់មានគ្រូអប់រំពិសេសរបស់សិស្សមួយរូប ឬបុគ្គលណាមួយដែលមានលក្ខណៈសមស្របចូលរួម គឺមិនត្រូវឱ្យមានអ្នកផ្តល់សេវាអប់រំពិសេស ចូលរួមតិចជាងមួយនាក់ឡើយ ។ បុគ្គលនេះ គួតែជាបុគ្គលដែលជា ឬជាបុគ្គលដែលនឹងត្រូវទទួលខុសត្រូវលើការអនុវត្តសកម្មភាព IEP ។ ឧទាហរណ៍ ប្រសិនបើសិស្សមានពិការភាពចំពោះការនិយាយ គ្រូអប់រំពិសសស ឬអ្នកផ្តល់សេវាអប់រំពិសេស គួតែជាអ្នកឯកទេសខាងជំងឺពិបាកនិយាយ ។34 C.F.R. § 300.321 cmts. នៅ 71 F.R. 46670
- តំណាងមណ្ឌលសិក្សាស្រុក ដែលជាអ្នកមាន :
  - លក្ខណៈសម្បត្តិគ្រប់គ្រាន់អាចផ្តល់ជូនបាន ឬអាចទទួលខុសត្រូវបានលើការផ្តល់ការបង្រៀនដែលមានការរៀបចំជាពិសេស ដើម្បីអាចឆ្លើយតបបានចំពោះតម្រូវការជាក់លាក់របស់សិស្សពិការ
  - ចំណេះដឹង អំពីកម្មវិធីការអប់រំពិសេស ព្រមទាំង
  - ចំណេះដឹងអំពីធនធាននានាដែល ភ្នាក់ងារសាធារណៈអាចផ្តល់ជូនបាន
- បុគ្គលដែលអាចយល់បាននូវការណែនាំចំពោះការបង្រៀនដែលស្មុគ្រស្មាញ ចំពោះលទ្ធផលនៃការវាយតម្លៃ ដែលអាចជាសមាជិកក្រុម ដូចមានរៀបរាប់ពីខាងលើស្រាប់
- ចំពោះការយល់ព្រម ឬការសម្រេចចិត្តដ៏ជាក់លាក់របស់មាតាបិតា ឬភ្នាក់ងារផ្សេងទៀត បុគ្គលដទៃដែលមានចំណេះដឹង ឬមានជំនាញពិសេស ស្តីអំពីសិស្ស ដោយរួមទាំងបុគ្គលនានាដែលផ្តល់សេវាដែលពាក់ព័ន្ធ តាមការសមស្រប ព្រមទាំង
- តាមលក្ខណៈជាក់ស្តែង សាមីសិស្សត្រូវចូលជាសមាជិកផងដែរ ។

មណ្ឌលសិក្សាស្រុក ត្រូវចាត់វិធានការ ដើម្បីធានាថា មាតាបិតាតែមួយ ឬទាំងពីរនាក់ ត្រូវមានវត្តមាននៅគ្រប់ការប្រជុំក្រុម IEP ឬមានឱកាសចូលរួមនៅគ្រប់ការប្រជុំនេះ ។ ចំណុចនេះមានន័យថា មណ្ឌលសិក្សាស្រុក ត្រូវតែ :

1) ជូនដំណឹងដល់មាតាបិតាសិស្សអំពីការប្រជុំ ឱ្យបានឆាប់ ដើម្បីធានាថា ពួកគាត់មានឱកាស ក្នុងការចុលរួម ព្រមទាំង
2) រៀបចំកាលវិភាគការប្រជុំ ដោយមានការយល់ព្រមទាំងអស់គ្នា ចំពោះពេលវេលា និងទីកន្លែង ។

បើមាតាបិតារូបណាមិនអាចចូលរួមប្រជុំក្រុម IEP បាន មណ្ឌលសិក្សាស្រុក ត្រូវតែប្រើមធ្យោបាយផ្សេងទៀត ដើម្បីធ្វើយ៉ាងណាឱ្យមាតាបិតារូបនោះអាចមានលទ្ធភាពចូលរួមប្រជុំក្រុម បានដោយមានរួមទាំងមធ្យោបាយការហៅទូរស័ព្ទជាលក្ខណៈបុគ្គល ឬជារបៀបខុនফ្រ៊ិន ផងដែរ ។ ការប្រជុំអាចធ្វើឡើងដោយមិនចាំបាច់មានវត្តមានមាតាបិតាសិស្ស ប្រសិនបើមណ្ឌលសិក្សាស្រុក មិនមានលទ្ធភាពធ្វើឱ្យពួកគាត់មកចូលរួមបាន ។ នៅក្នុងករណីនេះ មណ្ឌលសិក្សាស្រុកត្រូវតែរក្សាទុកនូវកំណត់ត្រា ចំពោះអ្វីដែលខ្លួនបានព្យាយាម រៀបចំការប្រជុំ ដោយមានការយល់ព្រមទាំងសងខាង ចំពោះពេលវេលា និងទីកន្លែង ដូចជា :

1) កំណត់ត្រាលំអិតអំពីការហៅទូរស័ព្ទ ឬការព្យាយាមហៅតាមទូរស័ព្ទ និងលទ្ធផលនៃការហៅទាំងនោះ
2) សំណៅថតចម្លងនៃការទំនាក់ទំនងតាមសំបុត្រ ដែលបានផ្ញើទៅកាន់មាតាបិតាសិស្ស និងការឆ្លើយតបណាមួយ ដែលបានទទួលពីមាតាបិតាសិស្ស ព្រមទាំង
3) កំណត់ត្រាលំអិតចំពោះការចុះទៅជួបដល់ផ្ទះមាតាបិតាសិស្សដោយផ្ទាល់ ឬការចុះទៅជួបនៅឯកន្លែងធ្វើការ ព្រមទាំងលទ្ធផលចំពោះការចុះទៅជួបទាំងអស់ ។

បន្ថែមពីលើបុគ្គលដែលត្រូវតែជាសមាជិកក្រុម IEP ដូចមានរៀបរាប់ខាងលើ សមាជិកក្រុមដូចខាងក្រោម ក៏ត្រូវតែអញ្ជើញឱ្យចូលរួមប្រជុំ IEP ផងដែរ ពេលដែលការប្រជុំមានបំណងពិចារណាលើគោលបំណងរបស់សិស្សក្រោយពេលរៀនចប់នៅមធ្យមសិក្សា និងសេវាអន្តរកាលដែលសិស្សត្រូវការ ដើម្បីជួយដល់រូបគេឱ្យមានលទ្ធភាពអាចដើរដល់គោលបំណងនោះបាន :

- សាមីសិស្ស តាមសភាពសមរម្យ ព្រមទាំង
- ជាមួយនឹងការយល់ព្រមរបស់មាតាបិតា ត្រូវឱ្យមានវត្តមានតំណាងភ្នាក់ងារដែលចូលរួម ដែលមានតួនាទីទទួលខុសត្រូវលើការផ្តល់សេវា ឬបង់ថ្លៃសេវាអន្តរកាល ( ភ្នាក់ងារនេះក៏អាចចាត់តាំងអ្នកដែលរៀបចំ IEP ឱ្យធ្វើជាតំណាងរបស់ខ្លួនបានផងដែរ) ។

ខបញ្ញត្តិរបស់រដ្ឋមីណេសូតា § 125A.515, subp. 5(b)(2) តម្រូវឱ្យមានសមាជិកក្រុមបន្ថែម សំរាប់សិស្សដែលត្រូវដាក់ឱ្យនៅក្នុងមន្ទីរផ្តល់ការថែទាំ និងព្យាបាល ចូលរួមផងដែរ ។ យោង : ខបញ្ញត្តិ សំរាប់គោលការណ៍ណែនាំបន្ថែម ។

សមាជិកនៃក្រុម IEP មិនតម្រូវឱ្យចូលរួមប្រជុំ IEP ទាំងមូល ឬដោយផ្នែកឡើយ ប្រសិនបើមាតាបិតារបស់សាមីសិស្សពិការ និងភ្នាក់ងារសាធារណៈយល់ព្រមជាលាយលក្ខណ៍អក្សរ ថាវត្តមានរបស់មាជិកមិនមានការចាំបាច់ឡើយ ពីព្រោះថាផ្នែកដែលសមាជិកទទួលខុសត្រូវនៅក្នុងកម្មវិធី ឬសេវាដែលពាក់ព័ន្ធនឹងខ្លួន មិនត្រូវបានធ្វើការកែប្រែ ឬមិនត្រូវបានលើកយកមកជជែកគ្នានៅក្នុងអង្គប្រជុំឡើយ ។

សមាជិកក្រុម IEP អាចសុំមិនចូលរួមប្រជុំ IEP ទាំងមូល ឬដោយផ្នែកបាន ពេលដែលការប្រជុំ ពាក់ព័ន្ធនឹងការកែប្រែ ឬការពិភាក្សាគ្នាលើផ្នែកដែលខ្លួនទទួលខុសត្រូវនៅក្នុងកម្មវិធី ឬសេវាដែលពាក់ព័ន្ធ ប្រសិនបើ :

- មាតាបិតាសិស្ស និងភ្នាក់ងារសាធារណៈ យល់ព្រមជាលាយលក្ខណ៍អក្សរចំពោះការមិនចូលរួមប្រជុំរបស់សមាជិក ដោយអនុលោមតាមខបញ្ញត្តិសុំមិនចូលរួមប្រជុំលេខ 34 C.F.R. § 300.9 ។ ការយល់ព្រមនេះ មានន័យថាមាតាបិតាសិស្សបានទទួលដំណឹងយ៉ាងពេញលេញនូវរាល់ពត៌មានទាំងអស់ ពាក់ព័ន្ធជាមួយនឹងសកម្មភាពដែលគេបានស្វែងរកការយល់ព្រម នៅក្នុងភាសា កំណើតរបស់គេ ឬតាមមធ្យោបាយផ្សេងទៀត ចំពោះការទំនាក់ទំនងគ្នា ។ មាតាបិតាត្រូវតែដឹង និងយល់ព្រមជាលាយលក្ខណ៍អក្សរ ចំពោះការអនុវត្តសកម្មភាព ដែលគេស្វែងរកការ យល់ព្រមពីខ្លួន ហើយការយល់ព្រមត្រូវតែរៀបរាប់នូវសកម្មភាពនោះ ហើយកត់ចូលនូវកំណត់ត្រា (បើមាន) ដែលនឹងត្រូវបញ្ជេញ ហើយថានឹងបញ្ជេញទៅឱ្យអ្នកណា ។ លើសពីនេះ ទៅទៀត មាតាបិតាសិស្សត្រូវតែយល់ថាការផ្តល់ការយល់ព្រមគឺជាការស្ម័គ្រចិត្ត ហើយអាចដកហូតមកវិញបានគ្រប់ពេល ។ ទោះជាយ៉ាងណាក៏ដោយ បើអ្នកដកហូតការយល់ព្រម មកវិញ ការដកហូតនេះ មិនអាចដូរទៀតបានឡើយ ព្រមទាំង
- សមាជិកត្រូវដាក់ជូនដល់មាតាបិតាសិស្សជាលាយលក្ខណ៍អក្សរ និងក្រុម IEP នូវអ្វីដែលខ្លួនចង់ដាក់បញ្ចូលទៅការបង្កើត IEP នៅមុនការប្រជុំ ។

**ប្រភេទនៃពិការភាពចម្បងរបស់កុមារ :**

សូមគូសលើប្រអប់នីមួយ១ខាងក្រោម ចំពោះប្រភេទនៃពិការភាព របស់សិស្ស ។ ទីន្ទ័យនេះមានសារៈសំខាន់សំរាប់ធ្វើរបាយការណ៍ ។ វាមិនមែនសំរាប់យកទៅបំរើឱ្យគោលបំណងនៃការបង្កើតកម្មវិធីឡើយ ដោយសារថា ការបង្កើតកម្មវិធី គឺអាស្រ័យលើតម្រូវការជាក់លាក់របស់សិស្ស គឺមិនសំអាងលើប្រភេទនៃពិការភាពដែលជាកត្តាកំណត់ចំពោះការមានសិទ្ធិទទួល IEP ។

- ❑ អត្តវិស័យប្លែកពីធម្មតា
- ❑ ថ្លង់ ខ្វាក់
- ❑ ថ្លង់ និងពិបាកស្តាប់
- ❑ ពិការភាពចំពោះការលូតលាស់ផ្នែកការយល់ដឹង
- ❑ ពិការភាពលើការលូតលាស់សតិបញ្ញា
- ❑ ពិការភាពផ្នែកអារម្មណ៍ ឬអាកប្បកិរិយា
- ❑ ពិការភាពផ្នែកសុខភាពផ្សេងទៀត
- ❑ ពិការភាពលើរាងកាយ
- ❑ ពិការធ្ងន់ធ្ងរ ច្រើនផ្នែក
- ❑ ពិការភាពចំពោះការរៀនសូត្រ
- ❑ ពិការភាពផ្នែកការនិយាយ ឬភាសា
- ❑ ភ្នែកពិបាកមើល
- ❑ របួសខួរក្បាលធ្ងន់ធ្ងរ

ភាសាចម្បងដែលប្រើនៅផ្ទះរបស់សិស្ស : _____ ត្រូវការអ្នកបកប្រែភាសា ក្នុងការទទួលសេវាទេ? □ បាទ/ចាស □ ទេ

ភាសាចម្បងរបស់សិស្ស : _____ ត្រូវការអ្នកបកប្រែភាសាក្នុងដំណើរការផ្លូវច្បាប់ទេ? □ បាទ/ចាស □ ទេ

**របាយការណ៍លើការរីកចំរើន :**

| **របាយការណ៍លើការរីកចំរើន** |
|---|
| តើពេលណាត្រូវធ្វើរបាយការណ៍ចំពោះការរីកចំរើន ឈានទៅរកការសម្រេចគោលបំណងប្រចាំឆ្នាំ ដល់មាតាបិតាសិស្ស? |

កត់ទុកនូវពេលវេលា និងវិធីដែលត្រូវរាយការណ៍ពីការរីកចំរើនរបស់សិស្សដល់មាតាបិតា ដូចជាតាមរយៈការប្រើប័ណ្ណរាយការណ៍ប្រចាំត្រីមាស ឬប័ណ្ណរាយការណ៍តាមកំឡុងពេលណាមួយផ្សេងទៀត ។ របាយការណ៍អំពីការរីកចំរើន ត្រូវមានន័យាយអំពីការរីកចំរើនរបស់សិស្ស ចំពោះការឈានទៅរកការសម្រេចបានលើគោលបំណង IEP ប្រចាំឆ្នាំ ។ របាយការណ៍អំពីការរីកចំរើន ត្រូវតែផ្តល់ឱ្យមាតាបិតាសិស្ស ឱ្យបានយ៉ាងហោចណាស់ក៏ស្មើនឹងចំនួនរបាយការណ៍ដែលមាតាបិតាបានទទួល អំពីការរីកចំរើនលើសិស្សដែលមិនពិការដែរ ។

**ទិន្នន័យដែលត្រូវយកមកធ្វើរបាយការណ៍ :**

**FOR AGENCY USE ONLY (Not part of IEP. See IEP instructions for code explanations.)**
**MARSS/Tuition Billing/Child Count data:**
**Primary Disability Code:_____** **Instructional Setting Code:_____**

ការចងក្រងឯកសារចំពោះកូដនៃពិការភាពចម្បង គឺត្រូវតែមាន សំរាប់យកទៅប្រើលើរបាយការណ៍តែប៉ុណ្ណោះ ។ វាមិនមែនជាផ្នែកមួយនៃ IEP ឬជាប្រធានបទសំរាប់ក្រុម IEP លើកយកទៅពិភាក្សាគ្នាឡើយ ។ ត្រូវចងក្រងជាឯកសារនូវពិការភាពចម្បង ក្រោមប្រភេទពិការភាពរបស់សិស្ស ។ តារាងខាងក្រោមបង្ហាញពីកូដនានា និងប្រភេទពិការភាពដែលពាក់ព័ន្ធ ។ ចំពោះករណីដែលសិស្សមានពិការភាព ច្រើនប្រភេទ ពិការភាពចម្បង គឺជាអ្វីដែលសិស្សត្រូវការសេវាច្រើនជាងគេ ។

| **កូដពិការភាព** | |
|---|---|
| 01 | ពិការភាពលើការនិយាយ/ភាសា |
| 02 | ពិការភាពចំពោះការលូតលាស់ផ្នែកការយល់ដឹង : តិច-មធ្យម |
| 03 | ពិការភាពចំពោះការលូតលាស់ផ្នែកការយល់ដឹង : មធ្យម-ធ្ងន់ធ្ងរ |
| 04 | ពិការភាពលើរាងកាយ |
| 05 | ថ្លង់-ពិបាកស្តាប់ |
| 06 | ភ្នែកពិបាកមើល |
| 07 | ពិការភាពចំពោះការរៀនសូត្រ |
| 08 | ពិការភាពលើអារម្ម/អាកប្បកិរិយា |
| 09 | ថ្លង់ ខ្វាក់ |
| 10 | ពិការភាពផ្នែកសុខភាពផ្សេងទៀត |
| 11 | អត្តវិស័យប្លែកពីធម្មតា |
| 12 | ពិការភាពលើការលូតលាស់សតិបញ្ញា |
| 14 | របួសខួរក្បាលធ្ងន់ធ្ងរ |
| 16 | ពិការធ្ងន់ធ្ងរ ច្រើនផ្នែក |

ការចងក្រងឯកសារអំពីកូដការរៀបចំការបង្រៀនរបស់សហព័ន្ធ គឺយកមកប្រើសំរាប់ការធ្វើរបាយការណ៍តែប៉ុណ្ណោះ ហើយវាមិនមែនជាផ្នែកមួយនៃ IEP ឡើយ ។ តារាងខាងក្រោមមានបង្ហាញជូនអំពីកូដនានា និងនិយមន័យរបស់វាសំរាប់លេខរៀង K-21 និង 3-K តាមលំដាប់លំដោយ ដូចតទៅ :

| ការរៀបចំការបង្រៀនរបស់សហព័ន្ធ សំរាប់សិស្ស K ឬរហូតដល់សិស្សមានអាយុ 21 ឆ្នាំ | |
|---|---|
| **ការរៀបចំការបង្រៀនរបស់សហព័ន្ធ** | **និយមន័យ** |
| **01** | សិស្សបានទទួលកម្មវិធីអប់រំមួយភាគធំ របស់គេនៅក្នុងថ្នាក់រៀនធម្មតា ។ រួមទាំងសិស្សពិការបានទទួលការអប់រំពិសេស និងសេវានានាដែលពាក់ព័ន្ធ នៅក្រៅម៉ោងរៀនធម្មតា ដែលមានចំនួនតិចជាង 21% នៃថ្ងៃសិក្សា ។ |
| **02** | សិស្សបានទទួលកម្មវិធីអប់រំ នៅក្នុងបន្ទប់ធនធាន ។ រួមទាំងសិស្សពិការ បានទទួលការអប់រំពិសេស និងសេវានានាដែលពាក់ព័ន្ធ នៅក្រៅម៉ោងរៀនធម្មតាចំនួនពី 21%-60% នៃថ្ងៃសិក្សា ។ |
| **03** | សិស្សបានទទួលកម្មវិធីអប់រំ នៅក្នុងថ្នាក់រៀនដាច់ដោយឡែកមួយ ដែលមានរួមទាំងសិស្សពិការ បានទទួលការអប់រំពិសេស និងសេវានានាដែលពាក់ព័ន្ធ នៅក្រៅម៉ោងសិក្សាធម្មតា មានចំនួនច្រើនជាង 60% នៃថ្ងៃសិក្សា ។ ចំណុចនេះ **មិនមាន** រួមបញ្ចូលនូវសិស្ស ដែលបានទទួលកម្មវិធីអប់រំនៅសាលាសាធារណៈ ឬសាលាឯកជន ឬនៅក្នុងសាលា ដែលសិស្សស្នាក់នៅ នៅក្នុងថ្ងៃសិក្សាដាច់ដោយឡែកមួយទេ ។ |
| **04** | សិស្សដែលបានទទួលកម្មវិធីអប់រំនៅក្នុងសាលាសាធារណៈ នៅថ្ងៃសិក្សាដាច់ដោយឡែកមួយ រួមទាំងសិស្សពិការ ដែលបានទទួលការអប់រំពិសេស និងសេវានានាដែលពាក់ព័ន្ធ នៅសាលាសាធារណៈក្នុងថ្ងៃដាច់ដោយឡែកមួយ មានចំនួនច្រើនជាង 50% នៃថ្ងៃសិក្សា ។<br><br>*ចំណាំ : នេះគឺត្រូវតែជាកម្មវិធី/សាលាដែលមានការរៀបចំជាពិសេស សំរាប់សិស្សទទួលការអប់រំពិសេស តែប៉ុណ្ណោះ ។* |
| **05** | សិស្សដែលបានទទួលកម្មវិធីអប់រំ នៅក្នុងសាលាឯកជននៅក្នុងថ្ងៃសិក្សាដាច់ដោយឡែកមួយ ដែលចំណាយដោយសាធារណៈ មានចំនួនច្រើនជាង 50% នៃថ្ងៃសិក្សា ។<br><br>*ចំណាំ : នេះគឺត្រូវតែជាកម្មវិធី/សាលាដែលមានការរៀបចំជាពិសេស សំរាប់សិស្សទទួលការអប់រំពិសេស តែប៉ុណ្ណោះ ។* |
| **06** | សិស្សដែលបានទទួលកម្មវិធីអប់រំ នៅសាលាសាធារណៈដែលសិស្សស្នាក់នៅ មានចំនួនច្រើនជាង 50% នៃថ្ងៃសិក្សា ។<br><br>*ចំណាំ : នេះគឺត្រូវតែជាកម្មវិធី/សាលាដែលមានការរៀបចំជាពិសេស សំរាប់សិស្សទទួលការអប់រំពិសេស តែប៉ុណ្ណោះ ដូចជាបណ្ឌិតសភារដ្ឋ សំរាប់មនុស្សថ្លង់ និងបណ្ឌិតសភារដ្ឋ សំរាប់មនុស្សខាក់ ។* |
| **07** | សិស្សដែលបានទទួលកម្មវិធីអប់រំនៅសាលារៀនឯកជនដែលសិស្សស្នាក់នៅ ដែលចំណាយដោយសាធារណៈ មានចំនួនច្រើនជាង 50% នៃថ្ងៃសិក្សា ។<br><br>*ចំណាំ : នេះគឺត្រូវតែជាកម្មវិធី/សាលាដែលមានការរៀបចំជាពិសេស សំរាប់សិស្សទទួលការអប់រំពិសេស តែប៉ុណ្ណោះ ។* |
| **08** | សិស្សដែលបានទទួលកម្មវិធីអប់រំ នៅតាមផ្ទះ/មន្ទីរពេទ្យ ។ នេះគឺរួមទាំងសិស្សពិការ ដែលបញ្ជូនឱ្យទៅរៀន និងបានទទួលការ អប់រំចំពោះកម្មវិធីសិក្សានៅមន្ទីរពេទ្យ ឬកម្មវិធីសិក្សានៅផ្ទះ ។ |

| ការរៀបចំការបង្រៀនរបស់សហព័ន្ធ សំរាប់ការអប់រំពិសេសដល់កុមារតូចដែលមានអាយុ 3ឆ្នាំ ចូលរៀននៅមត្តេយ្យសាលា | | |
|---|---|---|
| **ពេលធ្វើការកំណត់លើការរៀបចំការបង្រៀន សំរាប់កុមារដែលមានអាយុពី 3ដល់ 5ឆ្នាំ សូមប្រើកត្តាដូចខាងក្រោម ដើម្បីសម្រេចថាតើត្រូវយក MARSS មួយណា សំរាប់រៀបចំការបង្រៀនពិការភាពចម្បង មកប្រើ សំរាប់បង្រៀនកុមារនីមួយៗ ។** | | |
| **កត្តាដែលត្រូវប្រើដើម្បីកំណត់ការរៀបចំការបង្រៀនរបស់សហព័ន្ធ** | **ការរៀបរាប់អំពីកម្មវិធី** | **ការរៀបចំការបង្រៀនរបស់សហព័ន្ធ ដល់កុមារ** |
| **កុមារបានចូលរៀនជាមួយកម្មវិធីអប់រំកុមារមត្តេយ្យ ។** | កម្មវិធីអប់រំកុមារមត្តេយ្យ (EC) រួមទាំងយ៉ាងហោចណាស់ ក៏មានកុមារមិនពិការ 50%ផងដែរ ។<br><br>កម្មវិធី EC រួមទាំង តែក៏មិនកំណត់តែលើ :<br>• ថ្នាក់មុនមត្តេយ្យ<br>• ថ្នាក់មត្តេយ្យ<br>• កម្មវិធីមត្តេយ្យឯកជន<br>• ការត្រៀមកុមារមុនចូលរៀនបឋមសិក្សា<br>• ការអប់រំកុមារតូចជាគ្រួសារ<br>• ការថែទាំកុមារជាក្រុម ព្រមទាំង<br>• ដាក់ឱ្យសិស្សពិការ រៀនជាមួយសិស្សមិនពិការ នៅក្នុងថ្នាក់រៀនធម្មតា ដែលរួមបញ្ចូលយ៉ាងហោចណាស់ ក៏មានសិស្សមិនពិការ 50% ចូលរួម ។<br><br>វត្តមាននៅក្នុងកម្មវិធីអប់រំមត្តេយ្យ មិនចាំបាច់ត្រូវទទួលថវិកាឧបត្ថម្ភពី IDEA ផ្នែក ខ ទេ ។<br><br>**កំណត់ចំណាំលើពេលវេលាធ្វើដំណើរ :** ចំនួនពេលវេលាដែលកុមារចំណាយចំពោះការធ្វើដំណើរពីកម្មវិធី EC ធម្មតា ទៅកាន់កន្លែងផ្សេងទៀត ដើម្បីទទួលសេវាអប់រំពិសេស និងសេវានានាដែលពាក់ព័ន្ធ **មិនគួរ** បញ្ចូលទៅក្នុងការគណនាឡើយ ។ | **31** (នៅក្នុងកម្មវិធី EC ធម្មតា យ៉ាងហោចណាស់ក៏មានចំនួន 80% នៃពេលវេលាផងដែរ)<br><br>**32** (នៅក្នុងកម្មវិធី EC ធម្មតា ចំនួន 40-79% នៃពេលវេលា) ឬ<br><br>**33** (នៅក្នុងកម្មវិធី EC ធម្មតា ចំនួនតិចជាង 40% នៃពេលវេលា) ។<br><br>ក្នុងពេលកំណត់ថាតើត្រូវរាយការណ៍អំពីកុមារ ដោយការប្រើ ការរៀបចំការបង្រៀនទាំងនេះ អ្នកត្រូវតែគណនា នូវភាគរយនៃពេលវេលាដែលកុមារចំណាយនៅក្នុងកម្មវិធី EC ធម្មតា ។<br><br>តំណាងតួចែកនៃការគណនានេះ គឺជាបរិមាណពេលវេលាប្រចាំ សប្តាហ៍ ដែលកុមារចំណាយនៅក្នុងកម្មវិធី EC ធម្មតា ។ តួចែកគឺជាចំនួនសរុបនៃម៉ោងដែលកុមារចំណាយនៅក្នុងកម្មវិធី EC ធម្មតា **រួមទាំង** ពេលវេលាណាមួយ ដែលកុមារចំណាយដើម្បីទទួលការអប់រំពិសេស និងសេវាដែលពាក់ព័ន្ធ នៅក្រៅកម្មវិធី EC ធម្មតា ។ ចំពោះផលចែកត្រូវយកទៅគុណនឹង 100 ។ |
| **កុមារមិនបានចូលរៀនជាមួយកម្មវិធីអប់រំកុមារតូច ឬកម្មវិធី មត្តេយ្យ<br>ហើយបានចូលរៀនជាមួយកម្មវិធីអប់រំពិសេស ។** | កម្មវិធីអប់រំពិសេស គឺជាកម្មវិធីមួយដែលរួមបញ្ចូល តិចជាង 50% នៃកុមារមិនពិការ និងរួមបញ្ចូល តែក៏មិនកំណត់តែលើការបង្រៀនពិសេស និងសេវានានាដែលពាក់ព័ន្ធ ដែលមានផ្តល់ជូននៅក្នុង :<br>• ថ្នាក់រៀនការអប់រំពិសេស នៅក្នុង :<br>• អគារសិក្សាធម្មតា<br>• រចនេសណ្ឋាង ឬកន្លែងណាមួយ នៅក្រៅអាគារសិក្សាធម្មតា<br>• មន្ទីរថែទាំកុមារ<br>• មន្ទីរពេទ្យ ចំពោះអ្នកជំងឺមិនសំរាកពេទ្យ<br>• ការរៀបចំការសិក្សាណាមួយនៅសហគមន៍<br>• សាលាដាច់ដោយឡែកមួយ ព្រមទាំង<br>• អាគារសិក្សាដែលសិស្សស្នាក់នៅ ។ | **41** (បន្ទប់រៀនដាច់ដោយឡែក)<br><br>**42** (សាលារៀនដាច់ដោយឡែក)<br>• រួមទាំងថ្ងៃសិក្សានៅសាលារដ្ឋ និងសាលាឯកជន ដែលរៀបចំជាពិសេស សំរាប់កុមារពិការ ឬ<br><br>**43** (មន្ទីរដែលសិស្សស្នាក់នៅ)<br>• សាលាសិស្សស្នាក់នៅ ឬមន្ទីរពេទ្យទទួលអ្នកជំងឺសំរាក ។ |

| ការរៀបចំការបង្រៀនរបស់សហព័ន្ធ សំរាប់ការអប់រំពិសេសដល់កុមារតូចដែលមានអាយុ 3ឆ្នាំ ចូលរៀននៅមត្តេយ្យសាលា | | |
|---|---|---|
| ពេលធ្វើការកំណត់លើការរៀបចំការបង្រៀន សំរាប់កុមារដែលមានអាយុពី 3ដល់ 5ឆ្នាំ សូមប្រើកត្តាដូចខាងក្រោម ដើម្បីសម្រេចថាតើត្រូវយក MARSS មួយណា សំរាប់រៀបចំការបង្រៀនពិការភាពចម្បង មកប្រើ សំរាប់បង្រៀនកុមារនីមួយៗ ។ | | |
| **កត្តាដែលត្រូវប្រើដើម្បីកំណត់ការរៀបចំការបង្រៀនរបស់សហព័ន្ធ** | **ការរៀបរាប់អំពីកម្មវិធី** | **ការរៀបចំការបង្រៀនរបស់សហព័ន្ធ ដល់កុមារ** |
| **កុមារមិនបានចូលរៀនជាមួយកម្មវិធីអប់រំកុមារតូច ជាធម្មតា ឬកម្មវិធីអប់រំពិសេស ហើយបានទទួលសេវាអប់រំពិសេសរបស់ខ្លួនមួយចំនួន ឬទាំងអស់ នៅក្នុងផ្ទះ ។** | | 45 (ផ្ទះ)<br>• រួមទាំងកុមារ ដែលបានទទួលសេវាអប់រំពិសេសខ្លះ នៅឯទីកន្លែងអ្នកផ្តល់សេវា<br>• រួមទាំងអ្នកមើលថែកុមារ ដែលត្រូវស្នាក់នៅជាមួយ |
| **កុមារមិនបានទទួលសេវាអប់រំពិសេសណាមួយ នៅក្នុងកម្មវិធីអប់រំកុមារតូច កម្មវិធីអប់រំពិសេស ឬកម្មវិធីអប់រំតាមផ្ទះ ។** | | 44 (ទីកន្លែងរបស់អ្នកផ្តល់សេវា) |
| សំរាប់សេចក្តីលំអិតបន្ថែម និងការគណនាគំរូ សូមអានមេម៉ូ MDE ចុះថ្ងៃទី 10/10/06 "ការរាយការណ៍អំពីការរៀបចំការបង្រៀន សំរាប់កុមារពិការ មានអាយុពី 3-5 ឆ្នាំ" នៅឯគេហទំព័ររបស់ MDE ដែលមានផ្ទុកនូវបែបបទ IEP ទាំងនេះ ។ សូមចុចលើ Accountability Programs (កម្មវិធីគណនេយ្យភាព) ជ្រើសយក Compliance & Assistance (ការអនុលោមតាម និងជំនួយ) រួចជ្រើសយក Recommended Due Process Forms (បែបបទណែនាំឱ្យប្រើសំរាប់ដំណើរការផ្លូវច្បាប់) ។ | | |

## ក៏រិតជោគជ័យលើការសិក្សាបច្ចុប្បន្ន និងលទ្ធភាពជំនះបានលើពិការភាព គោលបំណង និងការវាស់វែងលើការរីកចំរើន : (PLAAFP)

មូលដ្ឋានគ្រឹះនៃ IEP គឺជាសេចក្តីផ្លែងអំពីក៏រិតជោគជ័យលើការសិក្សាបច្ចុប្បន្ន និងលទ្ធភាពជំនះបានលើពិការភាពរបស់សិស្ស (PLAAFP) ។ PLAAFP ត្រូវតែរៀបរាប់អំពីការប៉ះពាល់ចំពោះពិការភាពលើកម្មវិធីអប់រំចំណេះទូទៅរបស់សិស្ស ។ កម្មវិធីអប់រំចំណេះទូទៅ គឺដូចគ្នាទៅនឹងកម្មវិធីអប់រំសំរាប់សិស្សមិនពិការ ។ បើកុមារជាសិស្សមត្តេយ្យ PLAAFP ត្រូវតែមានរៀបរាប់អំពីការប៉ះពាល់ចំពោះពិការភាព លើការចូលរួមក្នុងសកម្មភាពសមស្របណាមួយ ។ លើសពីនេះទៅទៀត សំរាប់សិស្សដែលមានអាយុពី 14-21 ឆ្នាំ PLAAFP ត្រូវតែគិតគូរអំពីក៏រិតជោគជ័យបច្ចុប្បន្ន នៅក្នុងផ្នែកអន្តរកាលនីមួយៗ ដោយអនុលោមតាមច្បាប់រដ្ឋមីណេសូតា 3525.2900 ។ ផ្នែកទាំងនេះ អាចរួមបញ្ចូលទាំងការងារ ការសំរាក និងការកំសាន្ត ការរស់នៅឯផ្ទះ ការចូលរួមក្នុងសហគមន៍ និងការបណ្តុះបណ្តាលក្រោយរៀនចប់មធ្យមសិក្សា និងឱកាសរៀនសូត្រនានា ។

**គោលបំណងប្រចាំឆ្នាំដែលអាចវាស់វែងបាន ជាមួយនឹងបទដ្ឋានវាស់វែង ឬទិសដៅក្នុងរយៈពេលខ្លី :**

**____ នៃ ____ គោលបំណងប្រចាំឆ្នាំដែលអាចវាស់វែងបាន រួមទាំងការសិក្សា និងការជំនះលើពិការភាព ជាមួនឹងបទដ្ឋានវាស់វែង ឬទិសដៅរយៈពេលខ្លី :**

គោលបំណងការសិក្សា និងការជំនះលើពិការភាព ប្រចាំឆ្នាំដែលអាចវាស់វែងបាន ជាកម្លាំងចលករនាំឱ្យមានសេវា នៅក្នុង IEP ។ សំរាប់សិស្សដែលមានអាយុក្នុងសភាពអន្តរកាល គោលបំណង ក្រោយការរៀនចប់មធ្យមសិក្សាដែលអាចវាស់វែងបាន នឹងជាកម្លាំងចលកររបស់គោលបំណង និងសកម្មភាពប្រចាំឆ្នាំ ។ គោលបំណងការសិក្សា និងគោលបំណងជំនះលើពិការភាព ត្រូវតែឆ្លើយតប ចំពោះសេចក្តីត្រូវការរបស់សិស្ស ដែលបណ្តាលមកពីពិការភាពរបស់គេ ។ គោលបំណងនេះត្រូវរួមបញ្ចូលនូវបទដ្ឋានវាស់វែង ឬទិសដៅក្នុងរយៈពេលខ្លី ដែលនឹងបង្ហាញថាតើសិស្សរូបនេះ មានការរីកចំរើនឆ្ពោះទៅរកគោលបំណងដែរឬទេ ។ បំណងនៃគោលបំណងគឺដើម្បីជួយឱ្យសិស្សអាចចូលរួមបាន និងអាចមានការរីកចំរើន លើការអប់រំក្នុងកម្មវិធីចំណេះទូទៅ និងដើម្បី សម្រេចបាននូវសេចក្តីត្រូវការរបស់សិស្សលើការអប់រំផ្សេងទៀត ដែលបណ្តាលមកពីពិការភាពរបស់គេ ។ *សូមអាន* 34 C.F.R. § 300.320(a)(2)(i)(B) ។

**ការរីកចំរើនឆ្ពោះទៅកាន់ការសម្រេចបាននូវគោលបំណងប្រចាំឆ្នាំនេះ :**

រៀបរាប់ចំពោះការរីកចំរើន ឈានទៅរកការសម្រេចបាននូវគោលបំណងមួយនេះ ។ ជាលក្ខណៈជាក់លាក់ បទដ្ឋានសំរាប់វាស់វែង ឬទិសដៅក្នុងរយៈពេលខ្លី នឹងកំណត់អំពីរបៀបវាស់វែងលើការរីកចំរើន ។ របាយការណ៍រីកចំរើន ត្រូវប្រាប់ដល់មាតាបិតាសិស្សអំពីចំណុចត្រឹមណាដែលការីកចំរើនអាចទទួលយកបាន ដើម្បីអាចជួយឱ្យសិស្សសម្រេចបាននូវគោលបំណង នៅពេល

ដណ្ដាច់ឆ្នាំចូលមកដល់ ។ *សូមអាន* Minn. R. 3525.2810 ។ ត្រូវប្រើទិន្នន័យ និងមធ្យោបាយផ្សេងទៀត ដើម្បីសង្កេតអំពីការរីកចំរើន ឈានឆ្ពោះទៅរកគោលបំណង ។ នៅក្នុង ប្រយោគដែលសរសេរថា "ការរីកចំរើនរហូតមកដល់ _____" សរសេរបញ្ជូលនូវកាលបរិច្ឆេទចំពោះការរីកចំរើនដែលសរសេរចូលក្នុងរបាយការណ៍ មួយលើក។ ។ ការធ្វើបែបនេះ វាជួយឱ្យយើងអាចយករបាយការណ៍នេះមកធ្វើជាទិន្នន័យគោល សំរាប់ការវាស់វែងការរីកចំរើននាពេលអនាគត ហើយក៏បង្កើតបានជាមូលដ្ឋានសំរាប់ការកំណត់ថាតើការពិនិត្យឡើងវិញ នូវគោលបំណង មានភាពចាំបាច់ដែរឬទេ ។

**ភាពជោគជ័យ និងការវាស់វែងលើភាពរីកចំរើនរបស់សិស្ស :**

ក្នុងការបង្កើត IEP របស់សិស្សនីមួយ។ ក្រុម IEP ត្រូវតែពិចារណាលើ :

1) ចំណុចខ្លាំងទាំងឡាយរបស់សិស្ស
2) ក្តីកង្វល់នានារបស់មាតាបិតាសិស្ស ចំពោះការបង្កើនការអប់រំដល់សិស្ស
3) លទ្ធផលនៃការវាយតម្លៃដំបូង ឬការវាយតម្លៃថ្មី។បំផុតរបស់សិស្ស ព្រមទាំង
4) តម្រូវការលើការសិក្សា ការលូតលាស់ និងការជំនះលើពិការភាពរបស់សិស្ស ។
5) ក្នុងករណីសិស្សដែលអាកប្បកិរិយារបស់គេរារាំងដល់ការសិក្សារបស់ខ្លួន ឬអ្នកដទៃ ត្រូវពិចារណាលើការធ្វើអន្តរាគមន៍ និងការជ្រើសជ្រែងដោយប្រើអាកប្បកិរិយាជាវិជ្ជមាន និងយុទ្ធសាស្ត្រផ្សេងទៀត ដើម្បីដោះស្រាយលើបញ្ហានេះ ។
6) ក្នុងករណីរបស់សិស្សដែលភាពស្ទាត់ជំនាញភាសាអង់គ្លេសរបស់គេនៅមានកំរិត ត្រូវពិចារណាចំពោះសេចក្តីត្រូវការផ្នែកភាសារបស់សិស្ស ពាក់ព័ន្ធនឹង IEP របស់សិស្ស ។
7) ចំពោះករណីសិស្សខ្វាក់ភ្នែក ឬពិបាកមើល ក្រោយពេលធ្វើការវាយតម្លៃលើបំណិនអំណាន សេចក្តីត្រូវការ ព្រមទាំងមីឌាសមរម្យចំពោះការអាន និងការសរសេរ (រួមទាំងការវាយតម្លៃពីសេច ក្តីត្រូវការរបស់សិស្សនាពេលអនាគត ចំពោះការរៀនប្រើអក្សរសំរាប់មនុស្សខ្វាក់ និងការប្រើប្រាស់អក្សរនេះ) ត្រូវផ្តល់ការបង្ក្រៀនអំពីការប្រើអក្សរសំរាប់មនុស្សខ្វាក់ និងការប្រើអក្សរសំរាប់មនុស្សខ្វាក់ ប្រសិនបើក្រុម IEP មិនបានកំណត់ទេនោះ ថាតើការបង្ក្រៀនរបៀបប្រើអក្សរសំរាប់មនុស្សខ្វាក់ ឬការប្រើអក្សរសំរាប់មនុស្សខ្វាក់ មិនមានភាពសមរម្យសំរាប់សិស្សទេ ។
8) សេចក្តីត្រូវការលើការទំនាក់ទំនងរបស់សិស្ស ហើយក្នុងករណីនៃសិស្សថ្លង់ ឬពិបាកស្តាប់ ត្រូវពិចារណាលើសេចកីត្រូវការផ្នែកភាសា និងការទំនាក់ទំនងរបស់សិស្ស ឱកាសសំរាប់ការទំនាក់ទំនងដោយផ្ទាល់ជាមួយមិត្តភ័ក្តិ និងបុគ្គលិកបំរើការនៅក្នុងរបៀបការប្រើភាសា និងការទំនាក់ទំនងរបស់សិស្ស កំរិតការសិក្សា និងសេចកីត្រូវការពេញលេញ ដោយមានរួមទាំងឱកាសសំរាប់ការបង្ក្រៀនដោយផ្ទាល់ ដោយប្រើភាសា និងរបៀបទំនាក់ទំនងរបស់សិស្ស ។
9) ត្រូវពិចារណាថាតើសិស្សត្រូវការឧបករណ៍បច្ចេកវិជ្ជា និងសេវា ជាជំនួយដែរឬទេ ។

ការពិចារណាចំពោះកត្តាផ្សេង។ទាំងនេះ អាចចងក្រងជាឯកសារនៅក្នុង IEP ឬនៅក្នុងសំណេរជូនដំណឹងពីគ្រាមុន ឬទាំងពីរ ។ អ្វីដែលចងក្រងជាឯកសារគឺជាផ្នែកមួយនៃ IEP ដែលមិនចាំបាច់ចម្លងដាក់ក្នុងផ្នែកផ្សេងទៀតនៃ IEP ឡើយ ។

**ផែនការអន្តរកាល :**

សេវាអន្តរកាល មានន័យថា គឺជាសំណុំនៃសកម្មភាពមួយដែលមានការចាត់ចែងត្រឹមត្រូវ សំរាប់សិស្សពិការ ដែលត្រូវបានរៀបចំឡើង ពីដំណើរការ ដោយយកលទ្ធផលជាគោល ។ ដំណើរការនេះ ត្រូវ ផ្តោតលើការកែលំអភាពជោគជ័យក្នុងការសិក្សា និងការជំនះលើពិការភាពរបស់សិស្សពិការ ដើម្បីសម្របសម្រួលដល់ការធ្វើចលនាចំពោះសកម្មភាពនៅសាលា ទៅដល់សកម្មភាព ក្រោយការ រៀនសូត្ររបស់សិស្ស រហូតដល់សកម្មភាពក្រោយរៀនចប់នៅមធ្យមសិក្សា ការបណ្តុះបណ្តាលវិជ្ជាជីវ: ការងារចម្រុះ (រួមទាំងការជ្រើសជ្រែងលើការងារ) ការបន្តការសិក្សា និងការអប់ រំមនុស្សពេញវ័យ សេវាមនុស្សពេញវ័យ ការរស់នៅដោយឯករាជ្យ ឬការចូលរួមក្នុងសហគមន៍ ។ សេវាអន្តរកាល ត្រូវតែសំអាងលើសេចកតីត្រូវការរបស់សិស្សផងដែរ ដោយពិចារណាលើ ភាពខ្លាំង ការចូលចិត្ត និងចំណាប់អារម្មណ៍របស់សិស្ស ។ *សូមអាន* 34 C.F.R. § 300.43 ។

ការធ្វើផែនការអន្តរកាល សំរាប់សិស្សពិការត្រូវតែរួមបញ្ចូលនៅក្នុង IEP ដំបូង ដែលនឹងមានប្រសិទ្ធិភាពនៅថ្ងៃក់ទី9 ឬពេលដែលសិស្សមានអាយុគ្រប់ 14ឆ្នាំ ហើយចំណុចទាំងពីរនេះ គឺយកមួយ ណាដែលមកដល់មុន ។ ផែនការអន្តរកាលត្រូវតែធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ ។ អនុលោមតាមបទបញ្ញត្តិរបស់រដ្ឋមីណេសូតា § 125A.08(a)(1) ក្នុងការបង្កើតផែនការអន្តរកាលមណ្ឌល សិក្សាស្រុកត្រូវតែជូនដំណឹងដល់មាតាបិតាសិស្ស ឱ្យបានពេញលេញនូវគោលបំណងអន្តរកាល និងពាក់ព័ន្ធសេវានានា ដែលគួរយកមកពិចារណា ។ ផែនការនេះត្រូវរួមបញ្ចូលនូវ សេចក្តីថ្លែងអំពីសេចក្តីត្រូវការលើសេវាអន្តរកាល រួមទាំងសេចក្តីថ្លែងនៃការទទួលខុសត្រូវជាអន្តរភ្នាក់ងារ ឬការទំនាក់ទំនងគ្នា ឬយកចំណុចទាំងពីរ នៅមុនពេលសេវាបន្ទាប់បន្សំ ត្រូវបានសរុបជារូបរាងឡើង ។

| **សេវាអន្តរកាល**<br>**(ព័ត៌មានអន្តរកាលដែលត្រូវធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ)** |
|---|

**ក : គោលបំណងក្រោយការរៀនចប់មធ្យមសិក្សា ដែលអាចវាស់វែងបាន**

ការអប់រំ និងការបណ្តុះបន្ទាល ក្រោយរៀនចប់មធ្យមសិក្សា :

ការងារ :

ការរស់នៅដោយឯករាជ្យ (តាមភាពសមរម្យ ហើយអាចរួមបញ្ចូលនូវ សកម្មភាពសំរាក និងកំសាន្តកាយ ការចូលរួមក្នុងសហគមន៍ និងការរស់នៅឯផ្ទះ) :

ជាផ្នែកមួយនៃការធ្វើផែនការអន្តរកាល 34 CFR § 300.320(b)(1) តម្រូវឱ្យបញ្ចូលនូវគោលបំណងក្រោយមធ្យមសិក្សា ដែលអាចវាស់វែងបាន ទៅក្នុង IEP ដោយសំអាងលើ ភាពសមស្របនៃអាយុកាលការវាយតម្លៃលើអន្តរកាល ពាក់ព័ន្ធនឹងការអប់រំ និងការបណ្តុះបណ្តាលក្រោយរៀនចប់មធ្យមសិក្សា ការងារ ហើយតាមសភាពសមរម្យ បំណិន ការរស់នៅដោយឯករាជ្យ ។ គោលបំណងក្រោយការរៀនចប់នៅមធ្យមសិក្សា ដែលសិស្សសង្ឃឹមថាអាចសម្រេចបាន ក្រោយចាកចេញពីមធ្យមសិក្សា ។ គោលបំណងក្រោយការរៀនចប់នៅមធ្យមសិក្សាទាំងនេះ នឹងដឹកនាំផ្នែកទាំងអស់នៅក្នុង IEP ដែលនៅសល់ ដោយសារថាបំណងរបស់ IEP គឺដើម្បីត្រៀមរៀបចំសិស្សសំរាប់បន្តការសិក្សាបន្ថែមទៀត ការធ្វើការងារ និងតាមភាពសមរម្យ គឺត្រៀមរៀបចំសិស្សឱ្យចេះរស់នៅដោយឯករាជ្យ ។

**ខ : មុខវិជ្ជាសិក្សា**

| **ឆ្នាំសិក្សា** | **កំរិតថ្នាក់** | **មុខវិជ្ជា** |
|---|---|---|
| | 9 | |
| | 10 | |
| | 11 | |
| | 12 | |

ខែ និងឆ្នាំ ដែលរំពឹងថាសិស្សនឹងរៀនចប់ _____

បន្ថែមពីលើច្បាប់ក្នុងផ្នែក 34 CFR § 300.320(b)(2) មានបង្ហាញនូវសេវាអន្តរកាល រួមទាំងមុខវិជ្ជាសិក្សា ដែលមានភាពចាំបាច់ក្នុងការជួយដល់សិស្ស ឱ្យអាចចេះសម្រេចបាននូវ គោលបំណងក្រោយរៀនចប់នៅមធ្យមសិក្សារបស់គេ ។ មុខវិជ្ជាសិក្សា គឺមិនមែនជាការកត់ត្រានូវមុខវិជ្ជាទាំងឡាយដែលបានសិក្សារួចមកហើយនោះទេ តែគួរតែជាផែនការសិក្សាដែលមានរយៈពេលវែងមួយ ដែលជាការទស្សន៍ទាយចំពោះមុខវិជ្ជាដែលត្រូវសិក្សានាពេលអនាគត ។ មុខវិជ្ជាដែលបានសិក្សារួច ឬមុខវិជ្ជាដែលនឹងត្រូវសិក្សាអាចមានរួមទាំង ការងារនិងបច្ចេកទេសការរៀននៅឧត្តមសិក្សា និងការរៀនចំពោះកម្មវិធីដែលមានការសម្រួល ឬកែប្រែ ឬការសិក្សាដែលមានការរៀបចំជាពិសេសេស ដែលមានភាពឡើងទាត់ ក៏ដូចជា បទពិសោធន៍ការសិក្សាផ្សេងទៀត ដូចជា ការរៀនសូត្រនៅពេលធ្វើការ ។ ត្រូវកត់ត្រានូវឆ្នាំសិក្សាចំពោះសំណុំមុខវិជ្ជានីមួយៗដែលបានរៀនចប់ ឬមានផែនការនឹងបញ្ចប់ ។ មុខវិជ្ជាដែលត្រូវសិក្សា ត្រូវបង្ហាញនូវទំនាក់ទំងដោយផ្ទាល់ រវាងបទពិសោធន៍ការសិក្សារបស់សិស្សនៅវិទ្យាល័យ និងគោលបំណងក្រោយការរៀនចប់នៅមធ្យមសិក្សារបស់សិស្សដែលអាចវាស់វែងបាន ។

**គ : សេវាអន្តរកាល :**

| **សេវា** | **សកម្មភាព** | **ភ្នាក់ងារផ្តល់សេវានៅក្នុង IEP** |
|---|---|---|
| **ការបង្ក្រៀន (ដូចជា ការបង្ក្រៀនតាមបំណិនជាក់លាក់ ការអប់រំធម្មតា ការអប់រំដើម្បីការងារ និងបច្ចេកទេស) :** | | |
| **សេវាដែលពាក់ព័ន្ធ :** | | |
| **ការចូលរួមនៅក្នុងសហគមន៍ :** | | |

| | | |
|---|---|---|
| **ទិសដៅការអភិវឌ្ឍន៍ការងារ និងទិសដៅផ្សេងទៀត សំរាប់ការរស់នៅក្រោយរៀនចប់នៅមធ្យមសិក្សា :** | | |
| **បើសមរម្យ ត្រូវផ្តល់ជូននូវបំណិនជីវិតសំរាប់ការរស់នៅប្រចាំថ្ងៃ និងធ្វើការវាយតម្លៃការប្រើចលនារាងកាយជំនះលើពិការភាព :** | | |

សេវាអន្តរកាលមានរួមទាំងការបង្រៀន (ដូចជាការបង្រៀនបំណិនជាក់លាក់ ការអប់រំធម្មតា ការអប់រំដើម្បីការងារ និងបច្ចេកទេស) សេវានានាដែលពាក់ព័ន្ធ ការចូលរួមនៅក្នុងសហគមន៍ គោលបំណងការអភិវឌ្ឍន៍ការងារ និងគោលបំណងការរស់នៅជាមនុស្សពេញវ័យក្រោយការរៀនចប់នៅមធ្យមសិក្សា ហើយបើសមស្រប ការផ្តល់ជូននូវបំណិនជីវិតប្រចាំថ្ងៃ និងធ្វើការវាយតម្លៃការប្រើចលនារាងកាយជំនះលើពិការភាព ។ សេវាអន្តរកាល នៅក្នុងផ្នែកនេះ មានភាពពាក់ព័ន្ធយ៉ាងជិតស្និតជាមួយនឹងគោលបំណងប្រចាំឆ្នាំរបស់សិស្ស បទដ្ឋានសំរាប់វាស់វែង ឬទិសដៅក្នុងរយៈពេលខ្លី ។

សរសេរនូវសកម្មភាពដែលត្រូវធ្វើសំរាប់សេវាអន្តរកាល នៅក្នុងប្រឡោះទីពីរនៃតារាង ដែលត្រូវការ ដើម្បីជួយដល់សិស្ស ក្នុងការសម្រេចបាននូវគោលបំណងក្រោយការរៀនចប់នៅ មធ្យមសិក្សាដែលអាចវាស់វែងបានរបស់គេ ។ សកម្មភាពមួយអាចអនុវត្តបាន ដោយសហការជាមួយនឹងភ្នាក់ងារផ្សេងទៀតដែលចូលរួម ដោយរួមទាំងសាមីសិស្ស និងក្រុមគ្រួសារ ហើយ អាចមិនតម្រូវឱ្យមានការបង្រៀនបំណិនជាក់លាក់ ។

តាមការតម្រូវនៅក្នុង ច្បាប់ផ្នែកទី 34 CFR § 300.324 (c)(1) ប្រសិនបើភ្នាក់ងារដែលចូលរួម ក្រៅពីសាលារៀន ខកខានមិនបានផ្តល់ជូននូវ សេវាអន្តរកាលដល់សិស្ស ដូចមានរៀបរាប់នៅក្នុង IEP សាលាត្រូវតែកោះហៅប្រជុំក្រុម IEP ដើម្បីកំណត់រកយុទ្ធសាស្ត្រផ្សេងទៀត ដើម្បីសម្រេចគោលបំណងទាំងនោះឱ្យបាន ។ នៅក្នុងប្រឡោះចុងក្រោយនៃតារាង ត្រូវសរសេរឈ្មោះភ្នាក់ងារដែលចូលរួម ផ្តល់ជូននូវសេវាអន្តរកាល តាមការរៀបរាប់ ។

**ការផ្ទេរសិទ្ធិ :**

| **ការផ្ទេរសិទ្ធិពេលសិស្សគ្រប់អាយុជាមនុស្សពេញវ័យ** |
|---|
| សិទ្ធិទាំងអស់ដែលមាតាបិតាសិស្សមាន ដោយស្ថិតក្រោមផ្នែក ខ IDEA និងច្បាប់ផ្សេងទៀតរបស់រដ្ឋដែលពាក់ព័ន្ធ នឹងត្រូវផ្ទេរទៅឱ្យសិស្ស ពេលដែលសិស្សមានអាយុជាមនុស្សពេញវ័យ (18ឆ្នាំ) ប្រសិនបើមិនមានការចាត់តាំងឱ្យមានអាណាព្យាបាល ឬអ្នកទទួលខុសត្រូវស្របច្បាប់ទេនោះ ។<br><br>សិស្សនឹងបានទទួលដំណឹងអំពីការផ្ទេរសិទ្ធិនេះ នៅថ្ងៃទី _____ (កាលបរិច្ឆេទ) ។ |

ចាប់ផ្តើមមិនឱ្យយឺតជាងមួយឆ្នាំ នៅមុនពេលសិស្សមានអាយុគ្រប់ 18ឆ្នាំ នៅក្នុង IEP ត្រូវសរសេរចូលនូវសេចក្តីផ្លែងដែលនិយាយថា សាមីសិស្សបានទទួលដំណឹងនូវសិទ្ធិរបស់ខ្លួននៅក្រោម IDEA ដែលនឹងត្រូវផ្ទេរទៅឱ្យខ្លួន ពេលដែលខ្លួនមានអាយុគ្រប់ 18ឆ្នាំ ។ ពេលដែលសិស្សបានទទួលដំណឹងថានឹងមានការផ្ទេរសិទ្ធិនេះទៅឱ្យខ្លួន ត្រូវកត់ត្រាអំពីកាលបរិច្ឆេទដែលសិស្ស បានទទួលដំណឹងនេះ ចូលទៅក្នុង IEP ផងដែរ ។

**សេវា និងការកែសម្រួល :**

| **សេវា និងការកែសម្រួល** |
|---|

គោលបំណងនៃផ្នែកនេះរបស់ IEP គឺដើម្បីចងក្រងជាឯកសារនូវការអប់រំពិសេស និងសេវានានាដែលពាក់ព័ន្ធ ជំនួយបង្គ្រប់ ព្រមទាំងសេវា ដែលត្រូវផ្តល់ឱ្យសិស្ស ឬតាងនាមឱ្យសិស្ស ។ នៅក្នុងផ្នែកនេះ ក៏មានផ្តល់ជូននូវប្រឡោះទំនេរផងដែរ សំរាប់សរសេរនូវការកែសម្រួលកម្មវិធី ឬការជ្រើសជ្រែងនានា ដល់បុគ្គលិកសាលា ដែលនឹងត្រូវផ្តល់ជូន សំរាប់សិស្សឱ្យអាចលូតលាស់ឈានមុខបានយ៉ាងសមរម្យ ក្នុងការសម្រេចបាននូវគោលបំណងប្រចាំឆ្នាំ ដែលត្រូវពាក់ព័ន្ធ និងរីកចំរើន នៅក្នុងកម្មវិធីអប់រំទូទៅ និងដើម្បីចូលរួម សកម្មភាពក្រៅកម្មវិធីសិក្សា និងសកម្មភាព ក្រៅពីការសិក្សាផ្សេងទៀត ។

មានតារាងបី តារាងនីមួយ១មានប្រឡោះ 6 ដូច១គ្នា ដែលមានផ្តល់ជូននៅក្នុងបែបបទ IEP ដើម្បីពណ៌នានូវប្រភេទនៃសេវា និងការកែសម្រួល សម្រាប់សិស្ស ។ ប្រឡោះនីមួយ១អាចពង្រីកបាន តាមភាពជាក់ស្តែង ដើម្បីឱ្យមានកន្លែងទំនេរធំគ្រប់គ្រាន់ដែលចាំបាច់ សំរាប់សរសេរព័ត៌មានចូល ។ តារាងទាំងអស់ ជារូបតំណាងទូទៅសំរាប់យកមកប្រើ ដែលអាចជួយធានាបាននូវភាពដូច គ្នា ក៏ដូចជាផ្តល់ជូននូវព័ត៌មានដែលមានសារៈសំខាន់ សំរាប់ការអនុវត្តន៍ដ៏មានប្រសិទ្ធិភាពនូវ IEP ។ ការណែនាំពីរបៀបប្រើតារាងនីមួយ១ មានផ្តល់ជូនដូចខាងក្រោម ។

**ការអប់រំពិសេស និងសេវានានាដែលពាក់ព័ន្ធ :**

| ការអប់រំពិសេស និងសេវានានាដែលពាក់ព័ន្ធ (ការបង្រៀនចម្បងៗដោយផ្ទាល់ និងសេវាដែលត្រូវផ្តល់ជូនដោយផ្ទាល់) ។ | | | | | |
|---|---|---|---|---|---|
| សេចក្តីផ្លែងអំពីការអប់រំពិសេស និងសេវានានាដែលពាក់ព័ន្ធ | កាលបរិច្ឆេទចាប់ផ្តើម | ចំនួនដង/សប្តាហ៍/ខែ/ផ្សេងទៀត (ដូចជាប្រចាំថ្ងៃ Xក្នុងមួយសប្តាហ៍ តេស្តនីមួយៗ) | ចំនួននាទីសំរាប់សេវាមួយដង | ទីកន្លែង (ដូចជាថ្នាក់រៀនធម្មតា ក្រៅថ្នាក់/បន្ទប់ធនធាន បន្ទប់ការអប់រំពិសេស ផ្ទះ) | ការប៉ាន់ស្មានលើចិរវេលាសរុប |
| | | | | | |

នៅក្នុងប្រឡោះទីមួយ ត្រូវសរសេរអំពីការណែនាំលើការបង្រៀនជាក់លាក់ចំពោះការអប់រំពិសេស ដែលត្រូវផ្តល់ជូន ឬសរសេរអំពីសេវាជាក់លាក់ដែលពាក់ព័ន្ធ ។ ការណែនាំអំពី ការអប់រំពិសេស និងសេវានានាដែលពាក់ព័ន្ធ ត្រូវតែសំអាងលើការសិក្សាស្រាវជ្រាវមួយដែលមានការពិនិត្យពិច័យដោយអ្នកសិក្សាស្រាវជ្រាវផ្សេងទៀត ទៅក្នុងកំរិតមួយដែលអាចយក មកអនុវត្តបាន ។ ការនិយាយដោយជាក់លាក់គឺជារឿងចាំបាច់ ដើម្បីចងក្រងជាឯកសារថាតើការណែនាំដោយសំអាងលើការសិក្សាស្រាវជ្រាវ ឬសេវាដែលត្រូវផ្តល់ឱ្យសិស្ស បង្ហាញនូវភាព ស្របគ្នា ហើយក៏ដើម្បីជាការផ្តល់នូវការណែនាំច្បាស់លាស់ដល់បុគ្គលិកផងដែរ ។ ការណែនាំការបង្រៀន និងសេវាដែលត្រូវផ្តល់ជូន ត្រូវតែអាចជួយឱ្យសិស្សដើរទៅមុខបានយ៉ាងសមរម្យ ក្នុងការឈានទៅរកការសម្រេចបាននូវគោលបំណងប្រចាំឆ្នាំ ដែលពាក់ព័ន្ធនៅក្នុង និងមានការរីកចំរើននៅក្នុងកម្មវិធីអប់រំចំណេះទូទៅ ហើយក៏ដើម្បីសម្រេចបាននូវសេចក្តីត្រូវការលើការ អប់រំរបស់សិស្ស ចំពោះកម្មវិធីអប់រំផ្សេងទៀត ដែលបណ្តាលមកពីពិការភាពរបស់សិស្ស ។ *សូមអាន* 34 C.F.R §. 300.320(a)(2)(i)(B) ។ ក្រុម IEP ត្រូវតែជួបគ្នា ដើម្បី ពិនិត្យឡើងវិញ ហើយ បើចាំបាច់ ត្រូវធ្វើការកែប្រែ IEP បើសិស្សមិនមានការរីកចំរើនឈានទៅរកការសម្រេចបាននូវគោលបំណងប្រចាំឆ្នាំ និងសម្រេចបាននូវកម្មវិធីការអប់រំចំណេះទូទៅ តាមភាពសមរម្យ ។ *សូមអាន* 34 C.F.R. § 300.324(b) ។

នៅក្នុងប្រឡោះទីពីរ និងទីបី ត្រូវសរសេរអំពីកាលបរិច្ឆេទដែលនឹងត្រូវចាប់ផ្តើមការបង្រៀន និងការផ្តល់សេវាដែលបានរៀបរាប់ និងភាពញឹកញាប់នៃការបង្រៀន ព្រមទាំងការផ្តល់សេវាដែលជា សេចក្តីតម្រូវរបស់ IDEA ។

ប្រឡោះទីបួន ត្រូវកត់ត្រាអំពីចំនួននាទីដែលសេវា ឬការបង្រៀនត្រូវចំណាយ ក្នុងមួយលើកៗ ។ ព័ត៌មានេះ មានភាពចាំបាច់សំរាប់យកមកប្រើដើម្បីគណនាបរិមាណពេលវេលាដែលសិស្ស បានទទួលការអប់រំពិសេស និងសេវានានាដែលពាក់ព័ន្ធ និងបរិមាណពេលវេលាដែលសិស្សត្រូវបានគេយកចេញពីបន្ទប់រៀនធម្មតា បើត្រូវធ្វើដូច្នោះមែន ។ កំណត់ត្រានេះ នឹងជួយឱ្យ មណ្ឌលសិក្សាស្រុកអាចកំណត់បានត្រឹមត្រូវនូវការបង្កើតកូដការបង្រៀន និងដាក់ពាក្យសុំការបង់ចំណាយពីភ្នាក់ងារដែលពាក់ព័ន្ធ ។

នៅក្នុងប្រឡោះទីប្រាំ ត្រូវកត់ត្រាអំពីទីកន្លែងបង្រៀន ឬកន្លែងទទួលសេវា ដែលជាភាពតម្រូវរបស់ IDEA ។ ទីកន្លែងផ្តល់សេវា ក៏ជាផ្នែកមួយនៃការកំណត់កូដការរៀបចំការបង្រៀនផងដែរ ។ ព័ត៌មានេះ ត្រូវយកមកធ្វើការតាមដាននាពេលក្រោយ នៅលើបែបបទ ជាមួយនឹងការពន្យល់ ពីមូលហេតុ និងកំរិតដែលសិស្សនឹងមិនត្រូវចូលរួមការសិក្សាជាមួយសិស្សដទៃដែលមិនពិការ ។ (សូមអានអំពីការពន្យល់ ចំពោះបរិយាកាសដែលមានការតឹងរ៉ឹងតិចតួច (LRE) ) ។

នៅក្នុងប្រឡោះទីប្រាំមួយ ត្រូវកត់ត្រាចិរវេលាដែលត្រូវប្រើសំរាប់បង្រៀន និងផ្តល់សេវា ដោយអនុលោមតាម IDEA ។ ចំណុចនេះ អាចត្រូវកត់ទុកជាឯកសារតាមភាពសមរម្យ ដូចជា "សំរាប់ឆ្នាំសិក្សា" "12ខែ" "សំរាប់ឆមាស X" "នៅថ្ងៃទី [ខែ ថ្ងៃទី ឆ្នាំ] " ឬ "ក្នុងកំឡុងពេលសេវាពន្យារឆ្នាំសិក្សា" ។

**ជំនួយ និងសេវាបង្គ្រប់ :**

| ជំនួយ និងសេវាបង្គ្រប់ (ការកែសម្រួល ឧបករណ៍បច្ចេកវិជ្ជាសំរាប់ជំនួយ ជំនួយពីជំនួយការរបស់អ្នកឯកទេស ។ល។) | | | | | |
|---|---|---|---|---|---|
| សេចក្តីផ្លែងអំពីជំនួយ និងសេវាបង្គ្រប់ | កាលបរិច្ឆេទចាប់ផ្តើម | ចំនួនដង/សប្តាហ៍/ខែ/ផ្សេងទៀត (ដូចជាប្រចាំថ្ងៃ Xក្នុងមួយសប្តាហ៍ តេស្តនីមួយៗ) | ចំនួននាទីសំរាប់សេវាមួយដង | ទីកន្លែង (ដូចជាថ្នាក់រៀនធម្មតា ក្រៅថ្នាក់/បន្ទប់ធនធាន បន្ទប់ការអប់រំពិសេស ផ្ទះ) | ការប៉ាន់ស្មានលើចិរវេលាសរុប |
| | | | | | |

នៅក្នុងប្រឡោះទីមួយ ត្រូវសរសេរអំពីជំនួយ និងសេវាបង្ក្រប់ដ៏ជាក់លាក់ ដែលនឹងត្រូវផ្តល់ជូន ។ ជំនួយ និងសេវាបង្ក្រប់ ត្រូវតែសំអាងលើការសិក្សាស្រាវជ្រាវដែលបានទទួលការពិនិត្យពិច័យដោយអ្នកស្រាវជ្រាវផ្សេងទៀត លើកិរិតមួយដែលអាចអនុវត្តបាន ។ *សូមអាន* 34 C.F.R. § 300.320(a)(4) ។ ការសរសេរព័ត៌មានចូលត្រូវតែមានភាពជាក់លាក់ អំពី ជំនួយ ឬសេវា ប្រភេទណា ពីការសិក្សាស្រាវជ្រាវ ដែលត្រូវផ្តល់ជូន ដើម្បីបង្ហាញការស្របគ្នា និងដើម្បីផ្តល់ការណែនាំច្បាស់លាស់មួយដល់បុគ្គលិក ។ ជំនួយ និងសេវាបង្ក្រប់ ត្រូវតែជួយដល់សិស្សឱ្យមានលទ្ធភាពអាចធ្វើដំណើរទៅមុខបានយ៉ាងសមរម្យ ក្នុងការឈានទៅរកការសម្រេចបាននូវគោលបំណងប្រចាំឆ្នាំ ដែលពាក់ព័ន្ធនៅក្នុង ហើយរីកចំរើននៅក្នុងកម្មវិធីសិក្សាទូទៅ ហើយ សម្រេចបាននូវសេចក្តីត្រូវការរបស់សិស្សនៅក្នុងកម្មវិធីអប់រំផ្សេងទៀតដែលជាលទ្ធផលពីពិការភាពរបស់សិស្ស ។ *សូមអាន* 34 C.F.R. § 300.320(a)(2)(i)(B) ។ ច្បាប់របស់សហព័ន្ធ តម្រូវថា ក្នុងការផ្តល់ជូននូវ ឬការរៀបចំដើម្បីផ្តល់ជូននូវសេវាមិនពាក់ព័ន្ធនឹងការសិក្សា និងសេវាក្រៅកម្មវិធីសិក្សា ព្រមទាំងសកម្មភាពនានា ដោយរួមទាំងអាហារ ពេលសំរាក និងសេវា នានា ព្រមទាំងសកម្មភាពដែលបានរៀបចំនៅក្នុង § 300.107 ភ្នាក់ងារសាធារណៈនីមួយៗ ត្រូវធានាថាសិស្សពិការ នីមួយៗបានចូលរួមជាមួយសិស្សមិនពិការ នៅក្នុងសេវាក្រៅកម្មវិធីសិក្សា និងសកម្មភាពនានា ឱ្យបានកិរិតអតិបរមា ស្របតាមតម្រូវការរបស់សិស្សរូបនោះ ។ ភ្នាក់ងារសាធារណៈ ត្រូវធានា ថា សិស្សពិការមួយរូបៗ មានជំនួយ និងសេវាបង្ក្រប់ដែលកំណត់ដោយ ក្រុម IEP របស់សិស្ស ដែលមានភាពសមរម្យ និងចាំបាច់សំរាប់សិស្សអាចចូលរួមបាននៅក្នុងសកម្មភាព ដែលមិនមែន ជាសកម្មភាពសិក្សា ។ *សូមអាន* 34 C.F.R. § 300.117 ។ ឧបករណ៍ជំនួយបច្ចេកវិជ្ជា ការសម្រួលក្នុងថ្នាក់រៀន ជំនួយពីជំនួយការរបស់អ្នកឯកទេស និងសេវាប្រយោល ដើម្បីជួយ ដល់គ្រូ ដែលត្រូវបង្ក្រៀនសិស្ស គឺជាឧទាហរណ៍មួយនៃជំនួយ និងសេវាបង្ក្រប់ ។ បើសិនជាជំនួយរបស់ជំនួយការអ្នកឯកទេស គឺជាការតម្រូវ គឺមានន័យថា សេចក្តីត្រូវការរបស់សិស្ស និងការទទួលខុសត្រូវជាក់លាក់របស់ អ្នកផ្តល់ជំនួយ ត្រូវតែកត់ត្រាទុកក្រោម សេចក្តីថ្លែង ចំពោះជំនួយ និងសេវាបង្ក្រប់ ។

នៅក្នុងប្រឡោះទីពីរ និងទីបី ត្រូវសរសេរអំពីកាលបរិច្ឆេទដែលរំពឹងថាជំនួយ និងសេវាបង្ក្រប់ទាំងនោះនឹងត្រូវចាប់ផ្តើម អនុវត្តជំនួយ និងសេវាដែលបានរៀបរាប់រួចមកហើយ ព្រមទាំងចំនួនដងនៃការប្រើជំនួយ និងសេវា ទាំងនោះ តាមការតម្រូវរបស់ IDEA ។

នៅក្នុងប្រឡោះទីបួន ត្រូវកត់ត្រាអំពីចំនួននាទីនៃការប្រើជំនួយ ឬសេវាបង្ក្រប់ ដែលបានផ្តល់ជូនមួយលើកៗ តាមការសមរម្យ ។ កំណត់ត្រានេះ នឹងជួយឱ្យ មណ្ឌលសិក្សាស្រុកអាចកំណត់បានត្រឹមត្រូវនូវការបង្កើតកូដការបង្ក្រៀន និងដាក់ពាក្យសុំការបង់ចំណាយពីភ្នាក់ងារដែលពាក់ព័ន្ធ ។

នៅក្នុងប្រឡោះទីប្រាំ ត្រូវកត់ត្រាអំពីទីកន្លែងផ្តល់ជំនួយ ឬកន្លែងទទួលសេវា ដែលជាភាពតម្រូវរបស់ IDEA ។ ព័ត៌មាននេះមានភាពចាំបាច់សំរាប់បុគ្គលិក ឱ្យបបានដឹង អំពីពេលវេលា និងទីកន្លែង ដែលត្រូវអនុវត្ត ឬផ្តល់ជំនួយ ឬសេវា ។

នៅក្នុងប្រឡោះទីប្រាំមួយ ត្រូវកត់ត្រាថិរវេលាដែលត្រូវប្រើសំរាប់ការផ្តល់ជំនួយ ឬសេវា ដោយអនុលោមតាម IDEA ។ ចំណុចនេះ អាចត្រូវកត់ទុកជាឯកសារតាមភាពសមរម្យ ដូចជា "សំរាប់ឆ្នាំសិក្សា" "12ខែ" "សំរាប់ឆមាស X" "នៅថ្ងៃទី [ខែ ថ្ងៃទី ឆ្នាំ] " ឬ "ក្នុងកំឡុងពេលសេវាពន្យារឆ្នាំសិក្សា" ។

**ការសម្រួលកម្មវិធី និងការជ្រើមជ្រែង សំរាប់បុគ្គលិកសាលា :**

| **ការសម្រួលកម្មវិធី និងការជ្រើមជ្រែង សំរាប់បុគ្គលិកសាលា ( សម្រួលការបង្ក្រៀនដែលត្រូវផ្តល់ជូនសិស្ស ឬសមាសធាតុនានានៃកម្មវិធីធម្មតាផ្សេងទៀត សេវាប្រយោល ការបណ្តុះបណ្តាលជំនាញជាក់លាក់សំរាប់បុគ្គលិក ការអន្តរាគមន៍ដោយប្រើអាកប្បកិរិយា ។ល។** | | | | | |
|---|---|---|---|---|---|
| សេចក្តីថ្លែងអំពីការកែប្រែកម្មវិធី និងការជ្រើមជ្រែង ចំពោះបុគ្គលិកសាលា | កាលបរិច្ឆេទ ចាប់ផ្តើម | ចំនួនដង/សប្តាហ៍ /ខែ/ផ្សេងទៀត ( ដូចជាប្រចាំថ្ងៃ Xក្នុងមួយសប្តាហ៍ តេស្តនីមួយៗ) | ចំនួននាទី សំរាប់សេវា មួយដង | ទីកន្លែង ( ដូចជាថ្នាក់រៀនធម្មតា ក្រៅថ្នាក់/បន្ទប់ធនធាន បន្ទប់ការអប់រំពិសេស ផ្ទះ) | ការប៉ាន់ស្មានលើថិរវេលាសរុប |
| | | | | | |

នៅក្នុងប្រឡោះទីមួយ ត្រូវសរសេរអំពីការកែសម្រួលកម្មវិធី ឬការជ្រើមជ្រែងដ៏ជាក់លាក់សំរាប់បុគ្គលិកសាលា ដែលនឹងត្រូវផ្តល់ជូន ។ ការកែសម្រួលកម្មវិធី និងការជ្រើមជ្រែងសំរាប់បុគ្គលិកសាលា ត្រូវតែអាចជួយឱ្យសិស្សឈានទៅមុខបានយ៉ាងសមរម្យ ក្នុងការឆ្ពោះទៅរកការសម្រេចបាននូវគោលបំណងប្រចាំឆ្នាំ ដែលពាក់ព័ន្ធនៅក្នុង ហើយរីកចំរើននៅក្នុងកម្មវិធីសិក្សាទូទៅ ហើយ សម្រេចបាននូវសេចក្តីត្រូវការរបស់សិស្សនៅក្នុងកម្មវិធីអប់រំផ្សេងទៀតដែលជាលទ្ធផលពីពិការភាពរបស់សិស្ស ។ *សូមអាន* 34 C.F.R. § 300.320(a)(2)(i)(B) ។

នៅក្នុងប្រឡោះទីពីរ និងទីបី ត្រូវសរសេរអំពីកាលបរិច្ឆេទដែលរំពឹងថានឹងត្រូវចាប់ផ្តើម អំពីការកែសម្រួលកម្មវិធី និងការជ្រើមជ្រែងសំរាប់បុគ្គលិកសាលា ដូចមានការរៀបរាប់ពីខាងលើ ព្រមទាំងចំនួនដងនៃការប្រើ ការកែសម្រួលកម្មវិធី និងការជ្រើមជ្រែងសំរាប់បុគ្គលិកសាលា តាមការតម្រូវរបស់ IDEA ។

នៅក្នុងប្រឡោះទីបួន ត្រូវកត់ត្រាអំពីចំនួននាទីនៃការប្រើកម្មវិធី ដែលមានការកែសម្រួល និងការជ្រោមជ្រែងដល់បុគ្គលិកសាលា ដែលត្រូវផ្តល់ជូនមួយលើក១ តាមការសមរម្យ ។ កំណត់ត្រានេះ នឹងជួយឱ្យ មណ្ឌលសិក្សាស្រុកអាចកំណត់ បានត្រឹមត្រូវនូវការបង្កើតកូដការបង្ក្រៀន និងដាក់ពាក្យសុំការបង់ចំណាយពីភ្នាក់ងារដែលពាក់ព័ន្ធ ។

នៅក្នុងប្រឡោះទីប្រាំ ត្រូវកត់ត្រាអំពីទីកន្លែងចំពោះកម្មវិធី ដែលមានការកែសម្រួល និងការជ្រោមជ្រែងដល់បុគ្គលិកសាលា តាមការតម្រូវរបស់ IDEA ។ ព័ត៌មាននេះមានភាពចាំបាច់សំរាប់បុគ្គលិក ដើម្បីបានដឹង អំពីពេលវេលា និងទីកន្លែង ដែលត្រូវផ្តល់ ឬប្រើ កម្មវិធី និងការជ្រោមជ្រែងដល់បុគ្គលិកសាលា ដែលមានការកែសម្រួល ។

នៅក្នុងប្រឡោះទីប្រាំមួយ ត្រូវកត់ត្រាថិរវេលាដែលត្រូវប្រើសំរាប់កម្មវិធី ដែលមានការកែសម្រួល ឬការជ្រោមជ្រែងដល់បុគ្គលិកសាលា ដោយអនុលោមតាម IDEA ។ ចំណុចនេះអាចត្រូវកត់ទុកជាឯកសារតាមភាពសមរម្យ ដូចជា "សំរាប់ឆ្នាំសិក្សា" "12ខែ" "សំរាប់ឆមាស X" "នៅថ្ងៃទី [ខែ ថ្ងៃទី ឆ្នាំ] " ឬ "ក្នុងកំឡុងពេលសេវាពន្យារឆ្នាំសិក្សា" ។

**ការពន្យល់អំពីបរិយាកាសដែលមានភាពតឹងរ៉ឹងតិចតួច (LRE):**

| ការពន្យល់អំពីបរិយាកាសដែលមានភាពតឹងរ៉ឹងតិចតួច (LRE) |
|---|
| **ការពន្យល់** អំពីកំរិត ដែលសិស្សនឹងមិនចូលរួមជាមួយសិស្សមិនពិការ នៅក្នុងថ្នាក់រៀនធម្មតា និងសកម្មភាពផ្សេងទៀត ប្រសិនបើមាន។ *សូមអាន* 34 C.F.R. § 300.320(a)(5) ។ |

IDEA តម្រូវឱ្យមានបញ្ជូលការពន្យល់ ប្រសិនបើមាន នូវកំរិតដែលសិស្សនឹងមិនចូលរួមជាមួយសិស្សមិនពិការ នៅក្នុងថ្នាក់រៀនធម្មតា និងក្នុងសកម្មភាពក្រៅកម្មវិធីសិក្សា និងក្នុងសកម្មភាព មិនពាក់ព័ន្ធនឹងការសិក្សាផ្សេងអ្ទៀត ។

**ការវាយតម្លៃរបស់រដ្ឋ សំរាប់គណិតវិទ្យា :**

| ការវាយតម្លៃរបស់រដ្ឋ សំរាប់គណិតវិទ្យា | | |
|---|---|---|
| **អំណាន**<br>*(ថ្នាក់ទី 3, 4, 5, 6, 7, 8 និងថ្នាក់ទី10)*<br><br>សិស្សនឹងបានចូលរួមក្នុង :<br><br>☐ MCA ដោយមិនចាំបាច់មានការកែសម្រួល<br>☐ MCA ជាមួយនឹងការកែសម្រួល ដូចមានក្នុងតារាង :<br><br>ពន្យល់ពីរបៀបដែលថាការកែសម្រួលដែលបានជ្រើសរើស យកគឺជាការតំណាងនូវអ្វីទាំងអស់ដែលប្រើនៅក្នុងថ្នាក់រៀន ។<br><br>☐ MCA-កែប្រែ ជាការវាយតម្លៃដោយវិធីផ្សេងទៀត សំអាងលើបទដ្ឋានជោគជ័យលើកម្មវិធីកែសម្រួល ថ្នាក់ទី 5-8 និងថ្នាក់ទី 10 ។ ប្រសិនបើក្រុម IEP កំណត់ថា សិស្សនឹងត្រូវប្រឡង MCA-កែប្រែ IEP របស់សិស្សត្រូវតែ រួមបញ្ចូលផងដែរនូវបទដ្ឋានសំអាងលើគោលបំណង និងទិសដៅ ។<br><br>សរសេរទុកការសម្រេចចិត្តរបស់ក្រុម IEP: ពន្យល់ពីមូលហេតុ ដែលជំរើសលើការវាយតម្លៃនេះ មានភាពសមរម្យ ។ | **គណិតវិទ្យា**<br>*(ថ្នាក់ទី 3, 4, 5, 6, 7, 8 និងថ្នាក់ទី11)*<br><br>សិស្សនឹងបានចូលរួមក្នុង :<br><br>☐ MCA ដោយមិនចាំបាច់មានការកែសម្រួល<br>☐ MCA ជាមួយនឹងការកែសម្រួល ដូចមានក្នុងតារាង :<br><br>ពន្យល់ពីរបៀបដែលថាការកែសម្រួលដែលបានជ្រើសរើស យកគឺជាការតំណាងនូវអ្វីទាំងអស់ដែលប្រើនៅក្នុងថ្នាក់រៀន ។<br><br>☐ MCA- កែប្រែ ជាការវាយតម្លៃដោយវិធីផ្សេងទៀត សំអាងលើបទដ្ឋានជោគជ័យលើកម្មវិធីកែសម្រួល ថ្នាក់ទី 5-8 និងថ្នាក់ទី 11 ។ ប្រសិនបើក្រុម IEP កំណត់ថា សិស្សនឹងត្រូវប្រឡង MCA-កែប្រែ IEP របស់សិស្សត្រូវតែ រួមបញ្ចូលផងដែរនូវបទដ្ឋានសំអាងលើគោលបំណង និងទិសដៅ ។<br><br>សរសេរទុកការសម្រេចចិត្តរបស់ក្រុម IEP: ពន្យល់ពីមូលហេតុ ដែលជំរើសលើការវាយតម្លៃនេះ មានភាពសមរម្យ ។ | **វិទ្យាសាស្ត្រ**<br>*(ថ្នាក់ទី 5, 8 និងវិទ្យាល័យ)*<br><br>សិស្សនឹងបានចូលរួមក្នុង :<br><br>☐ MCA ដោយមិនចាំបាច់មានការកែសម្រួល<br>☐ MCA ជាមួយនឹងការកែសម្រួល ដូចមានក្នុងតារាង :<br><br>ពន្យល់ពីរបៀបដែលថាការកែសម្រួលដែលបានជ្រើសរើស យកគឺជាការតំណាងនូវអ្វីទាំងអស់ដែលប្រើនៅក្នុងថ្នាក់រៀន ។ |

| | | |
|---|---|---|
| ☐ តេស្ត MN នៃបំណិនការសិក្សា (MTAS) ជាការវាយតម្លៃមួយផ្សេងទៀត សំអាងលើភាពជោគជ័យលើ បទដ្ឋានមួយផ្សេងទៀត<br><br>សរសេរទុកអំពីការសម្រេចចិត្តរបស់ក្រុម IEP: ពន្យល់ពីមូលហេតុ ដែលជំរើសលើការវាយតម្លៃនេះ មានភាពសរម្យ ។ | ☐ តេស្ត MN នៃបំណិនការសិក្សា (MTAS) ជាការវាយតម្លៃមួយផ្សេងទៀត សំអាងលើភាពជោគជ័យលើ បទដ្ឋានមួយផ្សេងទៀត<br><br>សរសេរទុកអំពីការសម្រេចចិត្តរបស់ក្រុម IEP: ពន្យល់ពីមូលហេតុ ដែលជំរើសលើការវាយតម្លៃនេះ មានភាពសរម្យ ។ | ☐ តេស្ត MN នៃបំណិនការសិក្សា (MTAS) ជាការវាយតម្លៃមួយផ្សេងទៀត សំអាងលើភាពជោគជ័យលើ បទដ្ឋានមួយផ្សេងទៀត<br><br>សរសេរទុកអំពីការសម្រេចចិត្តរបស់ក្រុម IEP: ពន្យល់ពីមូលហេតុ ដែលជំរើសលើការវាយតម្លៃនេះ មានភាពសរម្យ ។ |

ដោះស្រាយសំរាប់ការវាយតម្លៃតាមកំរិតថ្នាក់របស់រដ្ឋ សំរាប់គណនេយ្យភាព ដែលត្រូវធ្វើឡើង នៅក្នុងអំឡុងពេល IEP ប្រចាំឆ្នាំរបស់សិស្ស ហើយសរសេរការសម្រេចចិត្ត IEP ទុកជាឯកសារ នៅក្នុង IEP ។ ការវាយតម្លៃគណនេយ្យភាពបច្ចុប្បន្ន គឺជាការវាយតម្លៃទូលំទូលាយរបស់រដ្ឋមីណេសូតា (MCA) ។ ប្រសិនបើការកែសម្រួលគឺជាការចាំបាច់ ដើម្បីវាស់វែង លើភាពជោគជ័យចំពោះការរៀនសូត្រ និងការជំនះលើពិការភាពរបស់សិស្ស ដែលត្រូវប្រឡង MCA ព័ត៌មានទាំងនោះ ត្រូវតែយកមកសរសេរទុកជាឯកសារនៅទីនេះ ។ ការកែសម្រួលមិនត្រូវធ្វើឱ្យពិន្ទុលើការប្រឡងរបស់សិស្សមិនមានសុពលភាពឡើយ ។ សំរាប់ព័ត៌មានបន្ថែម លើការកែសម្រួល សូមសំអាងលើជំពូកទី 5 នៃ *ទំរង់ការក្សួនខ្ជាតប្រើប្រាស់ សំរាប់ការវាយតម្លៃនៅរដ្ឋមីណេសូតា*។ ផ្លូវឈានទៅរកទំរង់ការក្សួនខ្ជាតប្រើប្រាស់ នៅលើគេហទំព័រ MDE គឺចុចលើ Accountability Programs (កម្មវិធីគណនេយ្យភាព)>Assessment and Testing (ការវាយតម្លៃ និងការធ្វើតេស្ត)> DAC Corner (ប្រឡោះរបស់ DAC|> Policies, Procedures and Guidelines (គោលនយោបាយ ទំរង់ការ និងគោលការណ៍ណែនាំ)

នៅមុនពេលដែលក្រុម IEP ជ្រើសរើសយក MCA-កែប្រែ ឬ MTAS សំរាប់មុខវិជ្ជាណាមួយ គេត្រូវតែពិនិត្យមើលឡើងវិញនូវគោលការណ៍ណែនាំបច្ចុប្បន្ន សំរាប់ *ភាពតម្រូវលើការមានសិទ្ធិប្រឡងដោយប្រើវិធីផ្សេងទៀត* ហើយធ្វើការកំណត់ថា ការវាយតម្លៃដែលបានជ្រើសយក គឺមានភាពសមរម្យសំរាប់សិស្សរូបនេះ ។ ភាពសមហេតុផលនៃការសម្រេចចិត្តនេះ ត្រូវតែសរសេរទុកនៅក្នុង IEP ។ ផ្លូវដើរទៅកាន់ *ភាពតម្រូវលើការមានសិទ្ធិប្រឡងដោយប្រើវិធីផ្សេងទៀត* មាននៅក្នុងគេហទំព័ររបស់ MDE ដោយត្រូវចុច Accountability Programs (កម្មវិធីគណនេយ្យភាព) > Assessment and Testing (ការវាយតម្លៃ និងការធ្វើតេស្ត)> Assessments (ការវាយតម្លៃ)> Alternate Assessments (ការវាយតម្លៃដោយវិធីផ្សេងទៀត) ។

ប្រសិនបើក្រុម IEP កំណត់ថា សិស្សត្រូវតែប្រឡង MCA-កែប្រែ IEP របស់សិស្សត្រូវតែមានរួមបញ្ចូលផងដែរនូវ គោលបំណង និងទិសដៅ សំអាងលើបទដ្ឋាន ។ សំរាប់ជំនួយលើការកំណត់ថា យើងត្រូវប្រើបទដ្ឋានមួយណា ក្រុមអាចអានគេហទំព័រ ឬទដ្ឋានការសិក្សារបស់ MDE នៅ Academic Excellence (ឧត្តមភាពការសិក្សា|> Academic Standards (បទដ្ឋានការសិក្សា) ។

| **ការវាយតម្លៃរបស់រដ្ឋ សំរាប់គណនេយ្យភាពចំពោះភាពស្ទាត់ជំនាញផ្នែកភាសាអង់គ្លេស** | |
|---|---|
| **អំណាន/ការសរសេរ** *(ថ្នាក់ K-12)*<br><br>សិស្សនឹងបានចូលរួមក្នុង :<br><br>☐ បញ្ជីត្រួតពិនិត្យអំណាន និងការសរសេរ K-2 (សំអាងលើការសង្កេតរបស់គ្រូ)<br>☐ តេស្តការសិក្សាភាសាអង់គ្លេស (TEAE) (អំណាន/ការសរសេរ) ដោយមិនមានការកែសម្រួល<br>☐ តេស្តការសិក្សាភាសាអង់គ្លេស (TEAE) ដោយមានការកែសម្រួល | **ការស្តាប់/ការនិយាយ** *(ថ្នាក់ K-12)*<br><br>សិស្សនឹងបានចូលរួមក្នុង :<br><br>☐ តារាងការសង្កេតភាសានិយាយរបស់សិស្សនៅរដ្ឋមីណេសូតា (MN-SOLOM) |

ដោះស្រាយនៅក្នុងអំឡុងពេល IEP ប្រចាំឆ្នាំរបស់សិស្ស សំរាប់សិស្សទទួលការអប់រំពិសេស ដែលជាអ្នកសិក្សាភាសាអង់គ្លេស (ELS) ។ សិស្សដែលត្រូវបានគេកំណត់ថា មានដែនកំណត់លើភាពស្ទាត់ជំនាញផ្នែកភាសាអង់គ្លេស (LEP) នៅក្នុង MARSS ត្រូវតែប្រឡងលើភាពស្ទាត់ជំនាញភាសាអង់គ្លេស (ELP) ដែលរួមបញ្ចូលនូវបញ្ជីត្រួតពិនិត្យលើអំណាន និងការសរសេរ K-2 តេស្តការសិក្សាភាសាអង់គ្លេស និង តារាងការសង្កេតភាសានិយាយរបស់សិស្សនៅរដ្ឋមីណេសូតា ។ ឆ្នាំសិក្សា 2010-2011 គឺជាឆ្នាំចុងក្រោយ ដែលការប្រឡង ELP ទាំងនេះ នឹងត្រូវធ្វើឡើង ។ រដ្ឋមីណេសូតា នឹងទទួលយកការប្រឡង ELP ថ្មី នៅឆ្នាំសិក្សា 2011-2012 ។

**កត្តានានាដែលត្រូវបំពេញដើម្បីអាចទទួលបានសញ្ញាប័ត្រ :**

| **កត្តានានាដែលត្រូវបំពេញដើម្បីអាចទទួលបានសញ្ញាប័ត្រ** |
|---|
| **ការតម្រូវលើការប្រឡងចេញដើម្បីបានទទួលសញ្ញាប័ត្រ (GRAD)**<br>ការប្រឡងដំបូងនៃអំណាន និងគណិតវិទ្យា GRAD ត្រូវមានភ្ជាប់នៅក្នុង MCA ។ ការប្រឡងវិញ្ញាសារសរសេរ GRAD ត្រូវធ្វើឡើងដំបូងនៅថ្នាក់ទី 9 ។ សិស្សអាចប្រឡង GRAD ឡើងវិញ ប្រសិនបើគេប្រឡងធ្លាក់លើវិញ្ញាសារសរសេរ GRAD ឬមួយថាគេមានពិន្ទុទាបជាងកំរិតជោគជ័យជាបទដ្ឋានលើ MCA ឬបានទទួលពិន្ទុជាប់លើអំណាន និងគណិតវិទ្យា ដែលមានភ្ជាប់ជាមួយនឹង GRAD ។ ក្រុម IEP អាចកំណត់នូវពិន្ទុដែលត្រូវចាត់ទុកថាជាការប្រឡងជាប់ សំរាប់សិស្សនីមួយៗ ក្រោយពេលការប្រឡង GRAD រួចមក ។ |
| សិស្សនឹងបានចូលរួមក្នុង :<br>☐ ដោយមិនចាំបាច់កែប្រែ :បញ្ជាក់មុខវិជ្ជា ។<br>☐ ជាមួយនឹងការកែប្រែ ដូចមានសរសេរក្នុងតារាង : បញ្ជាក់មុខវិជ្ជា ។<br>ពន្យល់ពីរបៀបដែលថាការកែសម្រួលដែលបានជ្រើសរើស យក គឺជាការតំណាងនូវអ្វីទាំងអស់ដែលប្រើនៅក្នុងថ្នាក់រៀន ។<br>☐ ជាមួយនឹងពិន្ទុដែលចាត់ទុកថាប្រឡងជាប់របស់សិស្សម្នាក់ៗ : បញ្ជាក់មុខវិជ្ជា ។ សរសេរចូលនូវពិន្ទុគោល ហើយពន្យល់ពីមូលហេតុ : |
| **តេស្តលើបំណិនជាមូលដ្ឋាន (BST)**<br>សិស្សដែលចូលរៀនថ្នាក់ទី 8 ដំបូង នៅឆ្នាំសិក្សា 2004-2005 ឬចូលរៀនមុននេះ អាចប្រឡង BST លើវិញ្ញាសារអំណាន និងគណិតវិទ្យា ដើម្បីបំពេញចំពោះភាពតម្រូវលើការប្រឡងចេញ ។ អំណាន និងគណិតវិទ្យា BST ត្រូវបានធ្វើឡើងតែសំរាប់ការប្រឡងឡើងវិញ ។ សិស្សដែលត្រូវប្រឡងឡើងវិញនូវតេស្តវិញ្ញាសារសរសេរ BST ត្រូវប្រឡងវិញ្ញាសារសរសេរ GRAD ។<br><br>សិស្សនឹងបានចូលរួមក្នុង :<br>☐ ដោយមិនចាំបាច់មានការកែសម្រួល :បញ្ជាក់ពីមុខវិជ្ជា ។<br>☐ ជាមួយនឹងការកែសម្រួល ដូចមានក្នុងតារាង : បញ្ជាក់ពីមុខវិជ្ជា ។<br>ពន្យល់ពីរបៀបដែលថាការកែសម្រួលដែលបានជ្រើសរើសយក គឺជាការតំណាងនូវអ្វីទាំងអស់ដែលប្រើនៅក្នុងថ្នាក់រៀន ។<br>☐ ជាមួយនឹងការកែសម្រួល/ពិន្ទុប្រឡងជាប់របស់សិស្សនីមួយៗ ក្រោយពីការប្រឡងលើកទី 1 :បញ្ជាក់ពីមុខវិជ្ជា សរសេរទុកនូវពិន្ទុគោល ការកែសម្រួលដែលបានជ្រើសរើស និងមូលហេតុ :<br>**ឬ**<br>☐ ជាមួយនឹងការប្រឡងដោយវិធីផ្សេងទៀតរបស់ MDE (ពិន្ទុប្រឡងជាប់របស់សិស្សនីមួយៗ) :បញ្ជាក់ពីមុខវិជ្ជា ហើយសរសេរទុកនូវពិន្ទុគោល :<br>☐ ជាមួយនឹងការប្រឡង MN ដោយវិធីផ្សេងទៀត-វិញ្ញាសារសរសេរ<br>☐ វិញ្ញាសារសរសេរ |
| **MCA-កែសម្រួល ឬ MTAS**<br>សិស្សក៏ប្រហែលជាត្រូវបំពេញភាពតម្រូវចំពោះការរៀនឱ្យបានចប់ តាមរយៈពិន្ទុការប្រឡងជាប់របស់សិស្សនីមួយៗ ដែលបានកំណត់ឡើងនៅក្នុងការប្រឡងដោយវិធីផ្សេងទៀត នៅក្នុងវិញ្ញាសារអំណាន និងគណិតវិទ្យា ។<br>☐ MCA-កែសម្រួល (ពិន្ទុប្រឡងជាប់របស់សិស្សនីមួយ) ប្រសិនបើជ្រើសយកវិញ្ញាសារគណនេយ្យភាពសរសេរ ឬគណិតវិទ្យាខាងលើ<br>☐ អំណាន ☐ គណិតវិទ្យា<br>☐ MTAS (ពិន្ទុប្រឡងជាប់របស់សិស្សនីមួយៗ) ប្រសិនបើជ្រើសយកវិញ្ញាសារគណនេយ្យភាពសរសេរ ឬគណិតវិទ្យាខាងលើ<br>☐ អំណាន ☐ គណិតវិទ្យា |

សរសេរទុកជាឯកសារអំពីផែនការការចូលរួមសំរាប់សិស្សនៅក្នុងការសម្រេចបាននូវភាពតម្រូវចំពោះភាពអាចបានទទួលសញ្ញាប័ត្របាក់ឌុប ដោយរួមទាំងការកែសម្រួលដែលបានប្រើប្រាស់នៅលើការប្រឡងចេញណាមួយ ។ ត្រូវចំណាំទុកថា ឆ្នាំសិក្សា 2011-2012 គឺជាឆ្នាំចុងក្រោយនៃការប្រឡង BST ។ ក្រោយពីឆ្នាំសិក្សា 2011-2012 ទៅ សិស្សដែលមានសិទ្ធិប្រឡង BST ហើយអ្នកដែលមិនបានបំពេញលើភាពតម្រូវចំពោះការប្រឡងចេញបាន តាមរយៈការប្រឡងដោយវិធីផ្សេងទៀតរបស់ MDE នឹងត្រូវប្រឡង GRAD ឡើងវិញ នៅក្នុងវិញ្ញាសារអំណាន ឬគណិតវិទ្យា ។ សំរាប់ព័ត៌មានបន្ថែមអំពី BST សូមសំអាងលើជំពូកទី 2 នៃ *ទំរង់ការក្សួនខ្នាតប្រើប្រាស់ សំរាប់ការប្រឡងនៅរដ្ឋមីណេសូតា*។ ទីកន្លែងសំរាប់ទទួលបានឯកសារស្តីអំពី *ទំរង់ការលើក្សួនខ្នាកប្រើប្រាស់* ដែលមាននៅលើគេហទំព័ររបស់ MDE គឺចុចលើ Accountability Programs (កម្មវិធីគណនេយ្យភាព|>Assessment and Testing (ការប្រឡង និងការធ្វើតេស្ត|> DAC Corner (ប្រឡោះរបស់ DAC|> Policies, Procedures and Guidelines (គោលនយោបាយ និងគោលការណ៍ណែនាំ) ។

**កំណត់ត្រា ឬស្ថានភាពចំពោះភាពស្ទាត់ជំនាញ ដែលសិស្សអាចសម្រេចបាននូវតម្រូវការនានាលើការប្រឡងចេញយកសញ្ញាប័ត្រ :**

| **កំណត់ត្រា ឬស្ថានភាពចំពោះភាពស្ទាត់ជំនាញ ដែលសិស្សអាចសម្រេចបាននូវតម្រូវការនានាលើការប្រឡងចេញយកសញ្ញាប័ត្រ** | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| **សម្រាប់ការប្រឡងជាប់ ឬប្រឡងជាប់នៅរដ្ឋ ត្រូវកត់ត្រាកាលបរិច្ឆេទដែលបានប្រឡងជាប់/សំរាប់ការប្រឡងជាប់ ឬពិន្ទុដែលសិស្សនីមួយ១ត្រូវប្រឡងជាប់ ត្រូវកត់ត្រានូវពិន្ទុ និងកាលបរិច្ឆេទដែលបានប្រឡងជាប់** | | | | | | | | | | | |
| | **ប្រឡងជាប់នៅរដ្ឋ** | **ប្រឡងជាប់** | | | | | **ពិន្ទុប្រឡងជាប់របស់សិស្សនីមួយ១** | | | | |
| **មុខវិជ្ជា** | **BST** | **GRAD** | **MCA** | **MCA-MOD** | **MTAS** | **ការវាយតម្លៃ វិធីផ្សេង MN - ការសរសេរ** | **BST ឬ ការវាយតម្លៃវិធីផ្សេង MDE** | **GRAD** | **MCA-MOD** | **MTAS** | **ការវាយតម្លៃ វិធីផ្សេង MN - ការសរសេរ** |
| **អំណាន (ថ្នាក់ទី 10)** | | | | | | | | | | | |
| **គណិតវិទ្យា (ថ្នាក់ទី 11)** | | | | | | | | | | | |
| **ការសរសេរ (ថ្នាក់ទី 9)** | | | | | | | | | | | |

សូមប្រើប្រឡោះទំនេរនេះ សំរាប់កត់ត្រាលើការបំពេញបានចំពោះតម្រូវការ ដែលអាចទទួលសញ្ញាប័ត្របាន ។

**ការប្រឡងទូទាំងរដ្ឋ :**

☐ ការប្រឡងទូទាំងរដ្ឋ **មិនមែន** ធ្វើឡើងនៅតាមកំរិតថ្នាក់ ដែលគ្របដណ្តប់ដោយ IEP នេះឡើយ ។

☐ ការប្រឡងទូទាំងរដ្ឋ **គឺជា** ការប្រឡងនៅតាមកំរិតថ្នាក់ ដែលគ្របដណ្តប់ដោយ IEP នេះ ។ (បើគេគូសលើប្រអប់នេះ សូមបន្តក្នុងតារាងខាងក្រោម)

| | | |
|---|---|---|
| **ការប្រឡងទូទាំងរដ្ឋ :** ចូរសរសេរចំពោះការប្រឡងនីមួយ១ ដែលធ្វើឡើងទូទាំងរដ្ឋ សំរាប់សិស្សទាំងអស់នៅក្នុងកំរិតនេះ ។ | **តើការប្រឡងមានភាពសមរម្យសម្រាប់សិស្សទេ?** *បង្ហាញដោយ បាទ/ចាស ឬទេ សំរាប់ការប្រឡងនីមួយ១ ។* | បើឆ្លើយថា **បាទ/ចាស** សម្រាប់ការប្រឡងនីមួយ១ ត្រូវបង្ហាញថាតើសិស្សត្រូវការវិញ្ញាសារបែបកែសម្រួល ហើយអ្វីខ្លះដែលត្រូវការកែសម្រួល ។<br><br>បើឆ្លើយថា **ទេ** សរសេរអំពីមូលហេតុដែលថាការប្រឡងទូទាំងស្រុកមិនសមរម្យចំពោះសិស្សរូបនេះ **ហើយ** បង្ហាញនូវអ្វីដែលជាការប្រឡងដោយប្រើវិធីផ្សេងទៀត ដែលត្រូវឱ្យសិស្សប្រឡង ព្រមទាំងប្រាប់ពីមូលហេតុដែលថាការកែសម្រួលនេះមានភាពសមរម្យចំពោះសិស្ស ។ |

ដោះស្រាយមួយលើកៗពេលសិស្សស្ថិតនៅក្នុងកំរិត ដែលសិស្សទាំងអស់ត្រូវបានធ្វើការប្រឡងដោយមណ្ឌលសិក្សាស្រុក ។ ត្រូវគូសលើចំណុចដែលត្រូវតាម IEP នេះ ។ បើការកែសម្រួលគឺជារឿងចាំបាច់ ដើម្បីវាស់វែងលើភាពជោគជ័យចំពោះការសិក្សា និងការយកជំនះលើពិការភាពរបស់សិស្ស លើការប្រឡងទូទាំងស្រុក ព័ត៌មានទាំងនោះ ត្រូវយកមកសរសេរ ចូលត្រង់នេះ ។ ការកែសម្រួលមិនត្រូវធ្វើឱ្យពិន្ធការប្រឡងរបស់សិស្សគ្មានសុពលភាពឡើយ ។

ប្រសិនបើក្រុម IEP កំណត់ថាការប្រឡងទូទាំងស្រុកណាមួយ មិនមានភាពសមរម្យចំពោះសិស្ស គេត្រូវតែឱ្យសិស្សចូលប្រឡងក្នុងវិធីផ្សេងទៀតដែលសមរម្យ ។ ក្រុម IEP ត្រូវតែសរសេរទុកជាឯកសារនូវមូលហេតុចំពោះការសម្រេចចិត្តមួយនេះ លើ IEP ។

**ការជូនដំណឹងដល់មាតាបិតាសិស្ស អំពីការប្រឡងដោយប្រើវិធីផ្សេង :**

| ការជូនដំណឹងដល់មាតាបិតាសិស្ស អំពីការប្រឡងដោយប្រើវិធីផ្សេង |
|---|
| ☐ បើគេគូសលើប្រអប់នេះ ភាពជោគជ័យលើការសិក្សារស់កូនអ្នក នឹងត្រូវវាស់វែងដោយប្រើបទដ្ឋានជោគជ័យលើការសិក្សាបែបកែសម្រួល ឬបទដ្ឋានភាពជោគជ័យលើ ការសិក្សាដោយប្រើវិធីផ្សេង ដូចបង្ហាញជូនពីខាងលើស្រាប់ លើការប្រឡងទូទាំងរដ្ឋ ឬទូទាំងមណ្ឌលសិក្សាស្រុក ។ ភាពស្ទាត់ជំនាញលើការសិក្សារបស់កូនអ្នក ជានិច្ចកាលត្រូវតែសំអាងលើបទដ្ឋានខ្ជឹមសារការសិក្សា សំរាប់កំរិតថ្នាក់របស់គេ ។ |

IDEA តម្រូវថា មាតាបិតាសិស្សត្រូវតែបានទទួលដំណឹង ពេលដែលកូនរបស់គាត់ត្រូវធ្វើការប្រឡង លើការប្រឡងដោយប្រើវិធីផ្សេងទៀត ហើយពួកគាត់ក៏ត្រូវតែបានទទួលដំណឹងថា ភាពជោគជ័យលើការសិក្សារបស់កូនគាត់ នឹងត្រូវវាស់វែងដោយបទដ្ឋានភាពជោគជ័យលើការសិក្សាបែបកែសម្រួល ឬវិធីផ្សេងទៀត ។ បទដ្ឋានភាពជោគជ័យលើការសិក្សាតាមបែបកែសម្រួល គឺជាការរំពឹងទុកនូវភាពជោគជ័យ សំអាងលើបទដ្ឋានតាមកំរិតថ្នាក់ ដែលជាការប្រឈមសំរាប់សិស្សដែលមានសិទ្ធិប្រឡងតាមវិធីនេះ តែក៏មានភាពពិបាកតិចជាងការប្រឡងតាមបទដ្ឋានដែលកំណត់ឡើងដើម្បីវាស់វែងភាពស្ទាត់ជំនាញ លើការប្រឡងចំណេះទូទៅ ។ បទដ្ឋានភាពជោគជ័យលើការសិក្សាតាមវិធីផ្សេង គឺជាបទដ្ឋានភាពជោគជ័យ ដែលប្រើប្រាស់ដើម្បីវាស់វែងលើភាពស្ទាត់ជំនាញរបស់សិស្ស ដែលមានសារៈសំខាន់ខ្លាំងលើពិការភាព ចំពោះការយល់ដឹង ។

*បែបបទនេះអាចរកបានតាមទ្រង់ទ្រាយផ្សេងទៀត ។ សូមទំនាក់ទំនងជាមួយនឹងប្រធាន IEP ដើម្បីស្នើសុំបែបបទនេះ តាមទ្រង់ទ្រាយផ្សេងទៀត ។*
*ក្រសួងអប់រំរដ្ឋមីណេសូតា (MDE) បានបង្កើតបែបបទដំណើរការផ្លូវច្បាប់តាមការណែនាំ សំរាប់ប្រើប្រាស់ដោយសហគមន៍អ្នកអប់រំ ។MDE បានបង្កើតឯកសារគោលការណ៍ណែនាំ សំរាប់បែបបទដំណើរការផ្លូវច្បាប់មួយចំនួនតាមការណែនាំ ដែលមានដាក់ផ្សាយនៅលើគេហទំព័ររបស់ខ្លួន ។ បំណងនៃឯកសារគោលការណ៍ណែនាំនេះ គឺធ្វើឡើងសំរាប់ផ្តល់ជាជំនួយដល់មាតាបិតាសិស្ស និងបុគ្គលិកបណ្ឌលសិក្សាស្រុក ពេលដែលខ្លួនប្រើនូវម៉ូដែលបែបបទដំណើរការផ្លូវច្បាប់តាមការណែនាំ ។ ការណែនាំ និងព័ត៌មាននៅក្នុងឯកសារគោលការណ៍ មិនមានមកជាមួយនូវដំបូន្ទានផ្លូវច្បាប់ ឬមួយថាគឺជាឯកសារជំនួសឱ្យឯកសារច្បាប់ សំរាប់ធ្វើការប្រឹក្សាយោបល់ ជាមួយនឹងមេធាវីដែលបានចុះបញ្ជីធ្វើឡើយ ។ ព័ត៌មានដែលមានបញ្ចូលនៅក្នុងឯកសារគោលការណ៍ណែនាំ មិនគួរចាត់ទុកជាឯកសារដែលអាចជឿជាក់បានថាជាឯកសារមានភាពទូលំទូលាយ ឬសំរាប់យកមកធ្វើជាគោលដើម្បីផ្ទឹយតបជាមួយនឹងស្ថានភាពផ្លូវច្បាប់ណាមួយរបស់អ្នកឡើយ ហើយឯកសារនេះអាចសរសេរមិនបានពេញលេញនូវការបកប្រែបានគ្រប់ជ្រុងជ្រោយដល់ច្បាប់រដ្ឋ និងសហព័ន្ធដែលនៅជាធរមានឡើយ ។*
*បែបបទនេះអាចធ្វើការ កែសម្រួលបានតាមសភាពជាក់ស្តែង ។*